ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តមណ្ឌលគិរី

សំណុំរឿងព្រហ្មទណ្ឌលេខ ២៤១

ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២០

សាលក្រមព្រហ្មទណ្ឌលេខ ៥៩

ចុះថ្ងៃទី ១៧ ខែមីនា ឆ្នាំ២០២១

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តមណ្ឌលគិរី

បានបើកសវនាការជាសាធារណៈ នាថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២១

ដែលមានសមាសភាពជំនុំជម្រះដូចខាងក្រោម៖

### សមាសភាពចៅក្រមជំនុំជម្រះ

លោកស្រី [redacted] ចៅក្រមជំនុំជម្រះ

### តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តមណ្ឌលគិរី

### ក្រឡាបញ្ជីសវនាការ

លោកស្រី [redacted] ក្រឡាបញ្ជី នៃសាលាដំបូងខេត្តមណ្ឌលគិរី

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ២៤១ ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២០ ដែលមានជនជាប់ចោទ:

១.ឈ្មោះ [redacted] **រតនា** ភេទប្រុស អាយុ៣៤ឆ្នាំ ជនជាតិខ្មែរ មុខរបរមន្ត្រីរាជការ កើតនៅ [redacted] រាជធានីភ្នំពេញ មានទីលំនៅបច្ចុប្បន្នភូមិមានលាភ សង្កាត់សុខដុម ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី កាន់សាសនាព្រះពុទ្ធ ប្រពន្ធឈ្មោះ [redacted] ស្រីពេជ្រ (លែងលះ) មានកូន ចំនួន០២ នាក់ ឪពុកឈ្មោះ [redacted] យឿន (រស់) ម្ដាយឈ្មោះ [redacted] សូរិយា (ស្លាប់) ប្រវត្តិផ្ដន្ទាទោសពីមុន គ្មាន ជាទីតិជន។

២.ឈ្មោះ [redacted] **សាវ៉ន** ភេទស្រី អាយុ៤១ឆ្នាំ ជនជាតិខ្មែរ មុខរបរជាមន្ត្រីរាជការ កើតនៅ [redacted] ខេត្តមណ្ឌលគិរី មានទីលំនៅបច្ចុប្បន្នភូមិ [redacted] ខេត្តមណ្ឌលគិរី កាន់សាសនាព្រះពុទ្ធ ប្ដីឈ្មោះ [redacted] ចាន់ថន មានកូនចំនួន០២នាក់ ឪពុកឈ្មោះ [redacted] យឿន (រស់) ម្ដាយឈ្មោះ [redacted] សូរិយា (ស្លាប់) កម្រិតវប្បធម៌ គ្រូបង្រៀន កំរិតមូលដ្ឋាន ប្រវត្តិផ្ដន្ទាទោសពីមុន គ្មាន ជាទីតិជន។

៣.ឈ្មោះ [redacted] **សុផល** ភេទស្រី អាយុ៤០ឆ្នាំ ជនជាតិព្នង មុខរបរមន្ត្រីរាជការ កើតនៅ [redacted] ខេត្តមណ្ឌលគិរី មានទីលំនៅបច្ចុប្បន្នភូមិ [redacted] ខេត្តមណ្ឌលគិរី កាន់សាសនាព្រះពុទ្ធ ប្ដីឈ្មោះ [redacted] ជ្រើង មានកូនចំនួន០៥ នាក់ ឪពុកឈ្មោះ [redacted] យឿន (រស់) ម្ដាយឈ្មោះ [redacted] សូរិយា (ស្លាប់) ប្រវត្តិផ្ដន្ទាទោសពីមុន គ្មាន ជាទីតិជន។

៤.ឈ្មោះ [redacted] **ឡន** ភេទប្រុស អាយុ៤៥ឆ្នាំ ជនជាតិព្នង មុខរបរមន្ត្រីរាជការ ទីកន្លែងកំណើតកើតនៅ [redacted] ខេត្តមណ្ឌលគិរី ទីលំនៅបច្ចុប្បន្នភូមិ [redacted]



Scanned with CamScanner

[redacted] ខេត្តមណ្ឌលគិរី កាន់សាសនាព្រះពុទ្ធ ប្រពន្ធឈ្មោះ [redacted] សម្ផស្ស មានកូនចំនួន០៣ នាក់ ឪពុកឈ្មោះ [redacted] យឿន (រស់) ម្ដាយឈ្មោះ [redacted] សូរិយា (ស្លាប់) កម្រិត វប្បធម៌ថ្នាក់ទី១២ ប្រវត្តិផ្ដន្ទាទោសពីមុនគ្មាន ជាទីតិជន ។

ជាប់ចោទពីបទ៖ **ហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត** ប្រព្រឹត្តនៅចំណុចភូមិពូលូង សង្កាត់រមនា ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី កាលពីអំឡុងខែមិថុនា ឆ្នាំ២០២០ បទល្មើសផ្ដន្ទាទោសតាមមាត្រា **២៤៨** និងមាត្រា **២៥៣** នៃច្បាប់ភូមិបាល។

ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សាវ៉ាន់** ភេទប្រុស អាយុ៥៦ឆ្នាំ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្នភូមិស្ពានក្អែក ឃុំកណ្ដែក ស្រុកប្រាសាទបាគង ខេត្តសៀមរាប។

ដោយមានមេធាវី [redacted] ជាមេធាវីតំណាងឱ្យដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សាវ៉ាន់**។

ដោយមានមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **សុផល**។

បានឃើញ ដីកាសន្និដ្ឋានស្ថាពរ លេខ ០៥/២១ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០២១ ។

បានឃើញ ដីកាដំណោះស្រាយ លេខ ៦១/២១ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០២១ ។

បានឃើញ ដីកាសម្រេចដាក់រឿងជំនុំជម្រះ លេខ ១២៣/២១ ចុះថ្ងៃ០៤ ខែកុម្ភៈ ឆ្នាំ២០២១ ។

## អង្គហេតុ និងដំណើររឿងមានដូចតទៅ

កាលពីអំឡុងខែមិថុនា ឆ្នាំ២០២០ នៅចំណុចភូមិពូលូង សង្កាត់រមនា ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី មានករណីហិង្សាទៅលើអ្នកកាន់កាប់ដោយសុចរិត បានកើតឡើងប្រព្រឹត្តដោយជនត្រូវចោទឈ្មោះ [redacted] រតនា ភេទប្រុស ,ឈ្មោះ [redacted] សាវ៉ន ភេទស្រី ,ឈ្មោះ [redacted] ឡុន ភេទប្រុស ,ឈ្មោះ [redacted] សុផល ភេទស្រី និងបក្ខពួក បានធ្វើសកម្មភាពដកបំផ្លាញបង្គោលរបងថ្មព្រំដី និងយកគ្រឿងចក្រមកឈូសឆាយដីរបស់ឈ្មោះ [redacted] សាវ៉ាន់ ដែលមានលិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លីលេខ ១៩៨/០៧ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០៧ ទទួលស្គាល់ដោយអាជ្ញាធរភូមិឃុំ ទាំងដែលជនត្រូវចោទទាំងបួននាក់ខាងលើ ពុំមានឯកសារពាក់ព័ន្ធអ្វីទាំងអស់។

## នាពេលសវនាការ ៖

-អំណានចម្លើយជនជាប់ចោទឈ្មោះ [redacted] **រតនា** បានសារភាពថា: ខ្លួនសុំបដិសេធចោលទាំងស្រុងលើពាក្យបណ្ដឹងរបស់ឈ្មោះ [redacted] សាវ៉ាន់ ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២០។ ដីទំនាស់ខាងលើមានទីតាំងដីស្ថិតនៅភូមិពូលូង សង្កាត់រមនា ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី មានទំហំ៣៧ហិកតា គឺជាដីដែលឪពុករបស់ខ្លួនឈ្មោះ [redacted] យឿង និងម្ដាយបានកាន់កាប់ប្រើប្រាស់អាស្រ័យផលតាំងពីឆ្នាំ១៩៩៤ មកម្ល៉េះ។ ចំពោះដីខាងលើនេះជារបស់ឪពុកម្ដាយខ្លួន គាត់បាននិយាយប្រាប់ខ្លួនថា គាត់មានឯកសារគ្រប់គ្រាន់ដែលទទួលស្គាល់ដោយអាជ្ញាធរមានសមត្ថកិច្ច។ តាំងពីពេលកាន់កាប់គ្រួសាររបស់ខ្លួនបានបង្កបង្កើនផលដូចជា ដាំកាហ្វេ ធុរេន ប័រ សាម៉ាវ សម្រាប់លក់។ កន្លងមកអំឡុងឆ្នាំ២០០៣ មានការឈូសឆាយលើកទី១៖ ខ្លួន និងបងខ្លួនឈ្មោះ [redacted] សាវ៉ន ក៏បានធ្វើការហាមឃាត់ពួកគេ (មិនស្គាល់ថា នរណាជាអ្នកឈូសឆាយ) មិនឱ្យធ្វើការឈូសឆាយ។ រហូតដល់ថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២០ ក៏មានការឈូសឆាយជាលើកទី២ ព្រមទាំងបានដកបង្គោលរបងទើបខ្លួនដឹងថាឈ្មោះ [redacted] សាវ៉ាន់ ជាអ្នកបញ្ជាកម្មករឱ្យមក



Scanned with CamScanner

ធ្វើការឈូសឆាយលើដីចំការចាស់របស់ឪពុកម្តាយខ្លួន ស្ថិតនៅភូមិពូលូង សង្កាត់រមនា ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី ពេលនោះខ្លួន និងបងរបស់ខ្លួនឈ្មោះ [redacted] សារ៉ន ,ឈ្មោះ [redacted] ឡុន បានធ្វើការហាមឃាត់ ពួកគេម្តងទៀត។ ក្រោយមកពួកខ្លួនក៏បានស្នើសុំឱ្យលោកអភិបាលក្រុង ជួយអន្តរាគមន៍ផ្អាកសកម្មភាពឈូសឆាយសិនរង់ចាំការដោះស្រាយនៅសាលាក្រុង ខណៈពេលនោះលោក មាស ចាន់នី និងកម្លាំងចម្រុះបានចុះទៅហាមឃាត់។ ខ្លួននិងបងប្អូនរបស់ខ្លួនពុំបានជេរប្រមាថទៅលើឈ្មោះ [redacted] សារ៉ាន់ ឬ ដកបង្គោលរបងនោះទេ។ នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០ លោក [redacted] វិបុល បានទាក់ទងមកបងប្អូនរបស់ខ្លួនឱ្យទៅសាលាក្រុងដើម្បីដោះស្រាយ បន្ទាប់មកពួកខ្លួន ក៏បានទៅសាលាក្រុងតាមការអញ្ជើញរបស់លោកអភិបាល ប៉ុន្តែពុំមានភាគីណាមួយចូលរួមដោះស្រាយឡើយ រហូតមកដល់បច្ចុប្បន្ន។ ក្រោយមកក៏ឃើញមានដីកាកោះហៅពីតុលាការតែម្តង។ ខ្លួនពុំបានបញ្ជាឱ្យអ្នកណាទៅប្រើអំពើហិង្សាលើជនរងគ្រោះណាមួយឡើយ។

-អំណានចម្លើយជនជាប់ចោទឈ្មោះ [redacted] សារ៉ន បានសារភាពថា: ចំការជារបស់ឪពុកឈ្មោះ [redacted] យឿន និងម្តាយរបស់ខ្លួនឈ្មោះ [redacted] សូរិយា ដែលមានទីតាំងស្ថិតនៅភូមិពូលូង សង្កាត់រមនា ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី ពិតមែន ហើយលិខិតកាន់កាប់ដីធ្លីគឺមិននៅនឹងខ្លួនទេ គឺនៅនឹងឪពុករបស់ខ្លួនដីចំការនោះមានទំហំ ៣៧ ហិកតា។ លុះដល់ថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២០ ខ្លួនក៏បានជិះម៉ូតូទៅទីតាំងដីដែលមានជម្លោះ និងបានជួបជាមួយបងប្រុសរបស់ខ្លួនឈ្មោះ [redacted] ឡុន និងប្អូនប្រុសរបស់ខ្លួន ឈ្មោះ [redacted] រតនា និងបានជួបជាមួយអ្នកកាសែតចំនួន០២នាក់ តែខ្លួនមិនស្គាល់ឈ្មោះទេ និងមិនបានឃើញឈ្មោះ [redacted] សារ៉ាន់ នៅទីនោះទេ ប៉ុន្តែបានឃើញគេបើកគ្រឿងចក្រចំនួន០២គ្រឿង កំពុងឈូសឆាយលើដីចំការឪពុករបស់ខ្លួន។ ស្របពេលនោះខ្លួនក៏បានសុំឱ្យអ្នកបើកគ្រឿងចក្រ នោះឈប់ឈូសឆាយដី តែគេមិនព្រមឈប់ឈូសឆាយនោះទេ។ ហើយពេលនោះខ្លួនក៏មិនបានជេរ និងមិនបានវាយបង្គោលរបងថ្មរបស់ឈ្មោះ [redacted] សារ៉ាន់ នោះដែរ ព្រោះខ្លួនមិនដែលស្គាល់ឈ្មោះ [redacted] សារ៉ាន់ និងឈ្មោះ [redacted] សុជាត នោះឡើយ។ នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០ ខ្លួន និងបងប្អូនរបស់ខ្លួន បានយកគ្រឿងចក្រទៅឈូសឆាយនៅលើដីចំការរបស់ឪពុកម្តាយរបស់ខ្លួន ដើម្បីឱ្យដឹងព្រំប្រទល់ដីឱ្យបានច្បាស់លាស់។ ចំពោះស្នាមមេដៃដែលបានដាក់ឈ្មោះខ្លួនលើលិខិតសេចក្តីបញ្ជាក់របស់អ្នកជាប់ព្រំប្រទល់ដីជាប់គ្នាចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០០៧ នោះគឺមិនមែនជាស្នាមមេដៃរបស់ខ្លួនទេ ព្រោះកាលនោះខ្លួនមិនបានផ្តិតមេដៃឱ្យឈ្មោះ [redacted] សុជាត ហើយ ខ្លួនក៏ពុំដែលស្គាល់ឈ្មោះ [redacted] សុជាត នោះដែរ។ ឪពុករបស់ខ្លួនឈ្មោះ [redacted] យឿន មានទីលំនៅភូមិមានលាភ សង្កាត់សុខដុមក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី។ ខ្លួនពុំបានបញ្ជាឱ្យអ្នកណាទៅប្រើអំពើហិង្សាលើជនរងគ្រោះណាម្នាក់ឡើយ។

-អំណានចម្លើយជនជាប់ចោទឈ្មោះ [redacted] ឡុន បានសារភាពថា: ខ្លួនសុំបដិសេធចោលទាំងស្រុងលើពាក្យបណ្តឹងរបស់ឈ្មោះ [redacted] សារ៉ាន់ ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២០ ដោយហេតុថា ខ្លួនពុំបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ។ ដីចំការជារបស់ឪពុកឈ្មោះ [redacted] យឿន និងម្តាយឈ្មោះ [redacted] សូរិយា ដែលមានទីតាំងស្ថិតនៅភូមិពូលូង សង្កាត់រមនា ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី ពិតមែន ដោយពួកគាត់បានកាន់កាប់តាំងពីឆ្នាំ១៩៩៤ មកម្ល៉េះ។ ចំពោះលិខិតកាន់កាប់ដីធ្លីខ្លួនមិនដឹងថា មានលិខិតកាន់កាប់ដីធ្លី ឬអត់នោះទេ។ ដីចំការខាងលើនេះមានទំហំ ៣៧ ហិកតា។ អំឡុង ពេលកាន់កាប់នោះ គ្រួសាររបស់ខ្លួនក៏បានដាំដំណាំបង្កបង្កើតផលដូចជា ដើម កាហ្វេ ធុរេន

សាម៉ាវ និងចិញ្ចឹមមាន់ គោ ទុកសម្រាប់លក់។ នៅអំឡុងឆ្នាំ២០០៣ អ៊ុំស្រីរបស់ខ្លួនឈ្មោះ [redacted] ប៉ាក់ បានប្រាប់ខ្លួនថាមានការឈូសឆាយដីរបស់គ្រួសារខ្លួនក្នុងនោះ មានឈ្មោះ [redacted] វិបុល និងពីរនាក់ទៀត មិនស្គាល់ឈ្មោះទេ។ រហូតដល់ថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២០ ប្អូនប្រុសរបស់ខ្លួនបានខលហៅខ្លួន ឱ្យទៅមើលគេឈូសឆាយដី និងដកបង្គោលរបងនៅ ពេលដែលខ្លួនទៅដល់ឃើញ មានគ្រឿងចក្រចំនួន០២គ្រឿង និងមានម៉ាស៊ីនខ្វងដីមួយគ្រឿងកំពុងតែធ្វើសកម្មភាព ឈូសឆាយដីខាងលើ និងមានកម្មករប្រហែលជា ១០ នាក់ ព្រមទាំងឃើញមនុស្សផ្សេងទៀត ប៉ុន្តែខ្លួនស្គាល់តែឈ្មោះ [redacted] សូរិយា តែម្នាក់ប៉ុណ្ណោះ អ្នកផ្សេងទៀតខ្លួនមិនស្គាល់ឡើយ។ ពេលនោះខ្លួន និងបងប្អូនពុំបានជេរប្រមាថទៅលើបុគ្គលឈ្មោះ [redacted] សាវ៉ាន់ ឬបំផ្លិចបំផ្លាញបង្គោលរបងទេ។ ក្រោយមកនៅថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២០ បងប្អូនរបស់ខ្លួនព្រមទាំងខ្លួនក៏បានឱ្យប្អូនស្រីរបស់ឈ្មោះ [redacted] សីហៈម៉ានី ទៅដល់ដាក់នៅសាលាក្រុង ដើម្បីសុំកិច្ចអន្តរាគមន៍ ដើម្បីបញ្ឈប់ការឈូសឆាយ និងដោះស្រាយដីទំនាស់ខាងលើ។ ខ្លួនពុំបានបញ្ជាឱ្យអ្នកណាទៅប្រើអំពើហិង្សាលើជនរងគ្រោះណាម្នាក់ឡើយ។

-ជនជាប់ចោទឈ្មោះ [redacted] **សុផល** បានសារភាពថាៈ ចំពោះពាក្យបណ្តឹងដែលឈ្មោះ [redacted] សាវ៉ាន់ ប្តឹងខ្លួនពីបទ ប៉ះពាល់កម្មសិទ្ធិឯកជន និងប្រើអំពើហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២០ នោះ គឺខ្លួន សូមបដិសេធ ព្រោះខ្លួនមិនបានប្រព្រឹត្តដូចដែលឈ្មោះ [redacted] សាវ៉ាន់ ប្តឹងនោះទេ។ ខ្លួនមានដីចំការរបស់ឪពុក ឈ្មោះ [redacted] យឿន និងម្តាយខ្លួនឈ្មោះ [redacted] សូរិយា ដែលមានទីតាំងស្ថិតនៅភូមិពូលូង សង្កាត់រមនា ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី ពិតមែន។ ហើយដីនោះមានលិខិតកាន់កាប់ ឬអត់នោះ គឺខ្លួនពុំបានដឹងនោះទេ។ ហើយកាលនោះ ខ្លួនបានដឹងថាដីឪពុកម្តាយរបស់ខ្លួន ខាងកើតជាប់នឹងភ្នំ ,ខាងលិចទល់អូរ ,ខាងត្បូងទល់អូរតូច និងខាងជើង ជាប់នឹងច្រកគរ ហើយដីរបស់ឪពុកម្តាយខ្លួនមានទំហំ ៣៧ ហិកតា។ កាលពីថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២០ គឺខ្លួនមិនបាននៅក្នុងហេតុការណ៍ដែលទៅហាមឃាត់គ្រឿងចក្ររបស់ឈ្មោះ [redacted] សាវ៉ាន់ ដែលបានឈូសឆាយដីរបស់ ឪពុកម្តាយរបស់ខ្លួននោះទេ។ ចំពោះស្នាមមេដៃដែលបានដាក់ឈ្មោះខ្លួន លើលិខិតសេចក្តីបញ្ជាក់របស់អ្នកមាន ព្រំប្រទល់ដីជាប់គ្នា ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០០៧ នោះ គឺមិនមែនជាស្នាមមេដៃរបស់ខ្លួននោះទេ ព្រោះកាលនោះ ខ្លួនមិនបានផ្តិតមេដៃទៅឱ្យឈ្មោះ [redacted] សុផាត នោះទេ។ ប៉ុន្តែកាលនោះគឺឈ្មោះ [redacted] សុផាត បានទៅជួបឪពុករបស់ខ្លួន ពេលនោះឪពុករបស់ខ្លួនបានឱ្យឈ្មោះ [redacted] សុផាត ទៅជួបជាមួយប្តីរបស់ខ្លួនឈ្មោះ [redacted] ជ្រើង ហើយ នៅពេលនោះប្តីរបស់ខ្លួនក៏បានផ្តិតមេដៃទៅលើលិខិតបញ្ជាក់ព្រំទៅឱ្យឈ្មោះ [redacted] សុផាត ប៉ុន្តែពេលនោះ ដែលឈ្មោះ [redacted] សុផាត យកឯកសារទៅឱ្យប្តីខ្លួនផ្តិតមេដៃនោះគឺនៅអំឡុងឆ្នាំ២០០៤។ បានជារូបខ្លួនអះអាងថា ដីចំការដែលមានទីតាំងស្ថិតនៅភូមិពូលូង សង្កាត់រមនា ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី ជាដីចំការរបស់ ឪពុកម្តាយរបស់ខ្លួន ព្រោះឪពុកម្តាយរបស់ខ្លួនអាស្រ័យផលតាំងពីឆ្នាំ១៩៩៤ មកម្លេះ និងបានដាំ ដំណាំកាហ្វេ ធូរេន និងដំណាំផ្សេងៗទៀត និងបានធ្វើផ្ទះ និងរស់នៅទីនោះផងដែរ ព្រមទាំងបានចិញ្ចឹមគោ ,មាន់ នៅទីនោះ ថែមទៀតផង។ ខ្លួនមានសាក្សីដឹងលឺដែលពួកគាត់អះអាងថា ដីចំការដែលមានទីតាំងខាងលើនោះ ជាដីចំការ ឪពុកម្តាយរបស់ខ្លួន គឺមានឈ្មោះ [redacted] សុខា ភេទប្រុស រស់នៅភូមិដោះក្រមុំ សង្កាត់សុខដុម ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី ឈ្មោះ [redacted] សាផាន ភេទប្រុស រស់នៅភូមិពូជ្រៃសែន សង្កាត់មនោរម្យ ក្រុងសែនមនោរម្យ ខេត្ត

មណ្ឌលគិរី ឈ្មោះ [redacted]ក់ពី ភេទប្រុស និងឈ្មោះ [redacted] ញ៉ិក។ ខ្លួនពុំបានបញ្ជាឲ្យអ្នកណាទៅប្រើអំពើហិង្សាលើជនរងគ្រោះណាឡើយ។

-អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សារ៉ាន់ បានឆ្លើយបំភ្លឺថា៖ កាលពីឆ្នាំ២០០៧ ខ្លួនទិញដីពីឈ្មោះ [redacted] សុផាត ស្ថិតនៅភូមិពូលូង ឃុំរមនា ស្រុកសែនមនោរម្យ ខេត្តមណ្ឌលគិរី ទំហំ ៦៧៥៥០ ម៉ែត្រការ៉េ ព្រមទាំងបានធ្វើលិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លីលេខ ១៩៨/០៧ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០៧ ដោយមានសាក្សី និងអាជ្ញាធរ ភូមិឃុំ ដឹងឮ ព្រមទាំងមានការឯកភាពផ្តិតមេដៃទទួលស្គាល់ព្រំដីពីអ្នកដែលមានព្រំដីជាប់គ្នាផងដែរ។ ក្រោយមកនៅឆ្នាំ២០០៧ ហ្នឹងដដែល ខ្លួនបានធ្វើការឈូសឆាយលើដីនេះទាំងស្រុងព្រមទាំងបានដាក់បង្គោល(ឈើ) របងព្រំ ថែមទៀតផង។ លុះដល់ឆ្នាំ២០១៤ ខ្លួនក៏បានធ្វើការឈូសឆាយម្តងទៀត។ រហូតដល់ឆ្នាំ២០១៧ ខ្លួនបានចាប់ផ្តើមធ្វើឈូសឆាយសារជាថ្មី និងបានដាក់បង្គោលដើងតាំងបន្ថែមត្រង់ចំណុចជ្រុងដីខាងលើ។ នៅថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២០ ខ្លួនបានដាក់បង្គោលរបងម្តងទៀតនៅលើដីរបស់ខ្លួន។ ក្រោយមកនៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០ ឈ្មោះ [redacted] សារ៉ែន ,ឈ្មោះ [redacted] សុផល ,ឈ្មោះ [redacted] សាឡុន ,ឈ្មោះ [redacted] រតនា និងបក្ខពួក បានយកគ្រឿងចក្រមកឈូសឆាយនៅលើដី ខ្លួនឃើញសកម្មភាពឈូសឆាយនេះដោយផ្ទាល់ ខ្លួនក៏បានប្តឹងទៅអាជ្ញាធរសង្កាត់រមនា និងអាជ្ញាធរក្រុងសែនមនោរម្យ ដើម្បីឲ្យធ្វើការហាមឃាត់ និងដោះស្រាយជូនខ្លួន។ ហើយអាជ្ញាធរក៏បានចុះទៅធ្វើការហាមឃាត់ដោយផ្ទាល់ពួកគេក៏បានផ្អាកសកម្មភាពទាំងនេះ។ ក្រោយមកខ្លួនបានរង់ចាំការដោះស្រាយពីអាជ្ញាធរ។ មានឈ្មោះ [redacted] សារ៉ែន ,ឈ្មោះ [redacted] សុផល ,ឈ្មោះ [redacted] សាឡុន ,ឈ្មោះ [redacted] រតនា និងបក្សពួក (មិនស្គាល់ ឈ្មោះ) បានស្រែកជេរខ្លួនទូវពាក្យអសុរសជាច្រើន ប៉ុន្តែធ្វើសកម្មភាពស្រែជេរខ្លាំងជាងគេឈ្មោះ [redacted] សារ៉ែន និងឈ្មោះ [redacted] សាឡុន។ ចំពោះការខូចខាតរួមមានបង្គោលរបងថ្មរស់រាប់រយដើម ព្រមទាំងបង្កការរាំងស្ទះដល់ការងាររបស់ខ្លួនព្រមទាំងពេលវេលាផងដែរ។ ហើយក៏មានអាជ្ញាធរលោក [redacted] អូន អភិបាលរងក្រុងសែនមនោរម្យ បានចូលរួមចុះហាមឃាត់ដោយផ្ទាល់ និងសំណូមពរមកតុលាការឲ្យជួយរកយុត្តិធម៌ដល់រូបខ្លួនផង ហើយខ្លួនទាមទារ សំណងជម្ងឺចិត្ត ចំនួន ១០០.០០០ (ដប់ម៉ឺន) ដុល្លារអាមេរិក។

-អំណានចម្លើយសាក្សីឈ្មោះ [redacted] អូន បានឆ្លើយបំភ្លឺថា: ខ្លួនបានពិនិត្យ និងដោះស្រាយលើពាក្យបណ្តឹងរបស់ឈ្មោះ [redacted] សារ៉ែន ,ឈ្មោះ [redacted] សុផល ,ឈ្មោះ [redacted] រតនា និងឈ្មោះ [redacted] សាឡុន ប្តឹងឈ្មោះ [redacted] សារ៉ាន់ ប៉ុន្តែឈ្មោះ [redacted] សូរិយា ធ្វើជាអ្នកតំណាងឲ្យឈ្មោះ [redacted] សារ៉ាន់។ នៅពេលដែលបានទទួលពាក្យបណ្តឹងរួចមក អាជ្ញាធរខាងសាលាក្រុងសែនមនោរម្យ ក៏បានធ្វើការកោះហៅភាគីទាំងសងខាងធ្វើការដោះស្រាយវិវាទ។ ក្រោយមកភាគីតំណាង ឈ្មោះ [redacted] សូរិយា ក៏បានចូលរួមព្រមទាំងមានឯកសារលិខិតកាន់កាប់ដីធ្លីលេខ ១៩៨ ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០០៧ ដោយឡែកភាគីឈ្មោះ [redacted] សុផល ពុំមានឯកសារពាក់ព័ន្ធការកាន់កាប់ដីទំនាស់ខាងលើនេះទេ និងពុំបានឆ្លើយបំភ្លឺអ្វីទេ ព្រមទាំងមានកាយវិការមិនសមរម្យនៅចំពោះមុខអាជ្ញាធរថែមទៀតផង។ នៅថ្ងៃកើតហេតុអំឡុងខែមិថុនា ឆ្នាំ២០២០ ឈ្មោះ [redacted] សារ៉ាន់ វេលាម៉ោងប្រហែលជាពេលរសៀល ខ្លួនជាអាជ្ញាធរបានដឹកនាំក្រុមការងារចុះទៅធ្វើការហាមឃាត់ សកម្មភាពឈូសឆាយរបស់ឈ្មោះ [redacted] សារ៉ែន។ បន្ទាប់មកភាគីឈ្មោះ [redacted] សារ៉ែន ,ឈ្មោះ [redacted] សុផល ,ឈ្មោះ [redacted] រតនា និងឈ្មោះ [redacted] សាឡុន បានជេរប្រមាថទូវពាក្យ



Scanned with CamScanner

អសុរសជាច្រើនមកលើឈ្មោះ [redacted] សារ៉ាន់ ពិតប្រាកដមែន។ ក្រោយមកភាគីខាងឈ្មោះ [redacted] សាវ៉ន ក៏បានផ្អាកសកម្មភាពរហូតមកដល់បច្ចុប្បន្នតែម្តង។

-សាក្សីឈ្មោះ [redacted] ទូច បានឆ្លើយបំភ្លឺថា: ខ្លួនបានស្គាល់ឈ្មោះ [redacted] **សារ៉ាន់** នៅអំឡុងឆ្នាំ២០០០ មកម្ល៉េះ ដោយសារពេលនោះខ្លួនធ្វើជាប៉ូលីសនៅខេត្តមណ្ឌលគិរី ហើយឈ្មោះ [redacted] សារ៉ាន់ ជាទាហ៊ានកងវិស្វកម្ម។ ខ្លួនបានដឹងថាឈ្មោះ [redacted] **សារ៉ាន់** ទិញដីដែលកំពុងមានទំនាស់ខាងលើ ស្ថិតនៅភូមិពូលូង សង្កាត់រមនា ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី ពីឈ្មោះ [redacted] **សុផាត** កាលពីអំឡុងឆ្នាំ២០០៧ មកម្ល៉េះ។ ចំណែកឈ្មោះ [redacted] សុផាត ត្រូវជាបងប្អូនរាប់អានគ្នាជាមួយខ្លួន ហើយខ្លួនក៏បានឃើញពិតប្រាកដថា ឈ្មោះ [redacted] សារ៉ាន់ បានដាក់បង្គោលរបងឈើ និងបង្គោលរបងថ្មជាបន្តបន្ទាប់ ព្រមទាំងមានការឈូសឆាយជារៀងរាល់ឆ្នាំ បន្ទាប់ពីទិញដីខាងលើពីឈ្មោះ [redacted] សុផាត។ លុះក្រោយមកនៅថ្ងៃមិនចាំអំឡុងខែមិថុនា ឆ្នាំ២០២០ វេលាម៉ោងប្រហែលជា៩ ជាងព្រឹក ខ្លួនបានឃើញមានអាជ្ញាធរក្រុង ចុះទៅធ្វើការផ្អាកសកម្មភាពគ្រឿងចក្រដែលកំពុងធ្វើការឈូសឆាយរបស់ឈ្មោះ [redacted] សាវ៉ន ព្រមទាំងមានការជជែកគ្នា។ បន្ទាប់មក ឈ្មោះ [redacted] រតនា ហៅ ធី ជាប្អូនបង្កើតរបស់ឈ្មោះ ចាន់ សាវ៉ន បានជេរនៅពាក្យអសុរសមកលើឈ្មោះ [redacted] សារ៉ាន់ ប្រាកដមែន។

-អំណានចម្លើយសាក្សីឈ្មោះ [redacted] **សូរិយា** បានឆ្លើយបំភ្លឺថា: ខ្លួនដឹងថាឈ្មោះ [redacted] **សារ៉ាន់** បានទិញដីដែលកំពុងមានទំនាស់ខាងលើពីឈ្មោះ [redacted] សុផាត កាលពីឆ្នាំ២០០៧ មកម្ល៉េះ។ ខ្លួនដឹងដោយសារតែមុនមកខ្លួនក៏ធ្លាប់លក់ដីឲ្យគាត់ដែរ ហើយខ្លួនក៏ធ្លាប់ទៅឈូសឆាយទីតាំងខាងលើកាលពីឆ្នាំ២០០៧ ឈូសឆាយបានចំនួន០១លើក និងឆ្នាំ២០១២ ឈូសឆាយដីព្រមទាំងធ្វើផ្លូវ និងដាក់បង្គោលរបង ព្រំបន្ថែម និងនៅឆ្នាំ២០១៧ ខ្លួនក៏បានឈូសឆាយដីខាងលើព្រមទាំងដាក់បង្គោលថ្មម្តងទៀត ហើយការឈូសឆាយ ចំនួន០២ដងមកនេះ គឺពុំមាននរណាមកហាមឃាត់ និងរករឿងនោះទេលុះដល់ឆ្នាំ២០២០ ឈ្មោះ [redacted] សារ៉ាន់ បានឲ្យឈូសឆាយដីនេះម្តងទៀតក៏មានរឿងកើតហេតុដូចការរៀបរាប់នៅខាងក្រោមតែម្តង។ លុះនៅថ្ងៃកើតហេតុប្រហែលជាថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០ វេលាម៉ោងប្រហែល៩ ព្រឹក ខ្លួនទៅឈូសឆាយដីខាងលើ និងដាក់បង្គោលព្រំថ្មថែម ជាមួយឈ្មោះ [redacted] សារ៉ាន់ ព្រមទាំងកម្មករ ស្រាប់តែមានមនុស្សមួយក្រុមជិះឡាន ម៉ាកពីរបាំង និងមានគ្នាប្រហែលជា១០ នាក់ ប៉ុន្តែខ្លួនស្គាល់តែឈ្មោះ [redacted] សាវ៉ន ,ឈ្មោះ [redacted] រតនា ,ឈ្មោះ [redacted] សុផល និងឈ្មោះ [redacted] ឡុន ចំណែកអ្នកផ្សេងទៀតខ្លួនមិនស្គាល់ឈ្មោះទេ ដោយពួកគេបានធ្វើការហាមឃាត់មិនឱ្យធ្វើការឈូសឆាយលើដីខាងលើ។ ហើយឈ្មោះ [redacted] សាវ៉ន បានបញ្ជាឲ្យកូនចៅរបស់ពួកគេកាចបង្គោលថ្មរស់ ជាច្រើនដើម និងបានជេរប្រមាថនូវពាក្យអសុរសជាច្រើនមកកាន់ខ្លួន និងឈ្មោះ [redacted] សារ៉ាន់ ហើយខ្លួន និងឈ្មោះ [redacted] សារ៉ាន់ ពុំបានធ្វើការតបតអ្វីនោះទេ។ ក្រោយមកនៅម៉ោងប្រហែលជា១១ ព្រឹក ឈ្មោះ [redacted] សារ៉ាន់ ក៏បាន ខលប្តឹងទៅអាជ្ញាធរក្រុងសែនមនោរម្យ ដើម្បីចុះមកពិនិត្យទីតាំងកំពុងមានទំនាស់ខាងលើ ហើយអាជ្ញាធរក្រុងសែនមនោរម្យ ក៏បានឱ្យឈ្មោះ [redacted] សារ៉ាន់ ផ្អាកសកម្មភាពឈូសឆាយដី និងដាក់បង្គោល ភ្លាមៗតែម្តង ដោយរង់ចាំការដោះស្រាយសិន។ ក្រោយមកប្រហែលជា ២ ទៅ ៣ ថ្ងៃបន្ទាប់ឈ្មោះ [redacted] សាវ៉ន ក៏បានយក គ្រឿងចក្រទៅធ្វើការឈូសឆាយលើដីខាងលើ បន្ទាប់មកឈ្មោះ [redacted] សារ៉ាន់ បានប្តឹងទៅអាជ្ញាធរ ម្តងទៀត ហើយអាជ្ញាធរក្រុងសែនមនោរម្យ បានចុះទៅធ្វើការហាម



Scanned with CamScanner

ឃាត់សកម្មភាពកំពុងឈ្លូសឆាយ។ នៅពេលនោះ ឈ្មោះ[redacted]ហាវ៉ន ក៏បានជេរប្រមាថមកពួកខ្លួន និងអាជ្ញាធរទូវពាក្យអសុរសជាច្រើនព្រមទាំងធ្វើការនិយាយបំភ្លៃថា ឈ្មោះ [redacted] សាវ៉ាន់ បានយកកាំភ្លើងគំរាមប្អូនរបស់គាត់ឈ្មោះ [redacted]តនា។

-សាក្សីឈ្មោះ [redacted]ុក បានឆ្លើយបំភ្លឺថា: នៅឆ្នាំ១៩៨៩ ខ្លួនជាសមាជិក លុះឆ្នាំ១៩៩៣ ខ្លួនបានធ្វើជាមេភូមិពូលូង ហើយនៅឆ្នាំ២០០៦ មានការបោះឆ្នោតជ្រើសរើសមេភូមិ ពេលនោះឈ្មោះ [redacted]ស្រេីន ជាប់ជាមេភូមិ ហើយខ្លួនជាអនុភូមិ រហូតមកដល់ឆ្នាំ២០១៧ ខ្លួនក៏បានឡើងធ្វើជា មេភូមិម្តងទៀត។ ចំពោះឈ្មោះ [redacted] រតនា , ឈ្មោះ [redacted] សាវ៉ន ,ឈ្មោះ [redacted] សុផល និងឈ្មោះ [redacted] ឡូន ព្រមទាំងឈ្មោះ[redacted] សាវ៉ាន់ ខ្លួនស្គាល់ច្បាស់គឺឈ្មោះ [redacted] ឡូន ក្រៅពីនោះធ្លាប់តែឮឈ្មោះ ប៉ុន្តែមិនស្គាល់មុខ។ ហើយខ្លួនក៏មិនដឹងច្បាស់ទេថា ពួកគេមានទំនាស់ដីធ្លី គ្រាន់តែដឹងថាឈ្មោះ [redacted] សាវ៉ាន់ ធ្លាប់ប្រមូលទិញដីពីប្រជាពលរដ្ឋនៅម្តុំខាងក្រោយផ្សារថ្មី ផ្លូវក្រវ៉ាត់ក្រុង ដែលស្ថិតនៅភូមិពូលូង សង្កាត់រមនា ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី។ កន្លងមកខ្លួនពុំធ្លាប់ឃើញឈ្មោះ [redacted]រតនា ,ឈ្មោះ [redacted] សាវ៉ន ,ឈ្មោះ [redacted] សុផល និងឈ្មោះ [redacted] ឡូន ចូលកាន់កាប់ និងធ្វើស្រែចំការលើដីនោះទេ ប៉ុន្តែពួកគេមានដីក្បែរនោះដែរ មានចំងាយពីគ្នាប្រហែលជា៥០០ ម៉ែត្រ ប៉ុន្តែខ្លួនមិនដឹងថាដីចំការរបស់ពួកគេមានទំហំប៉ុន្មានឡើយ។ ហើយកន្លងមកខ្លួន ក៏មិនដឹងថា ឈ្មោះ ចាន់ យឿន ធ្លាប់បានកាន់កាប់ដីនៅទីនោះទេ។

-សាក្សីឈ្មោះ [redacted] **សុផាត** បានឆ្លើយបំភ្លឺថា: ក្នុងឆ្នាំ២០០២ ខ្លួនទិញដីមានទំហំ ប្រាំមួយហិកតាជាង ពីឈ្មោះ អ៊ែល ដែលជាមេភូមិពូលូង (បច្ចុប្បន្នស្លាប់) ហើយបានធ្វើលិខិតលក់ទិញរវាងខ្លួន និងគាត់ ពេលនោះកូនចៅរបស់ឈ្មោះ អ៊ែល ក៏បានដឹងថា ខ្លួនទិញដីពីឪពុកគាត់ដែរ។ សព្វថ្ងៃលិខិតទិញលក់ដីរវាងខ្លួន និងឈ្មោះ អ៊ែល គឺបាត់ហើយ។ ក្រោយពេលទិញដីពីឈ្មោះ អ៊ែល ហើយ ខ្លួនបានឱ្យកូន និងកូនប្រសារ (មិនចាំឈ្មោះ) របស់ឈ្មោះ អ៊ែល កាប់ឆ្ការព្រៃ និងធ្វើរបងដើម្បីកំណត់ព្រំដី។ ដីរបស់ឈ្មោះ [redacted] យឿន គឺមានព្រំប្រទល់ជាប់នឹងដីរបស់ខ្លួន ហើយឈ្មោះ [redacted] យឿន មិនដែលមកប៉ះពាល់ ឬ ឈ្លូសឆាយចូលដីរបស់ខ្លួននោះទេ។ ខ្លួនមិនដឹងថាឈ្មោះ [redacted] យឿន បានធ្វើសកម្មភាពអ្វីខ្លះនៅលើដីរបស់គាត់ទេ ខ្លួនគ្រាន់តែដឹងថា មានព្រំដីជាប់គ្នាប៉ុណ្ណោះ។ លុះដល់ឆ្នាំ២០០៧ ខ្លួនបានលក់ដីដែលមានទំហំប្រហែល ប្រាំមួយហិកតាជាង ស្ថិតនៅភូមិពូលូង ឃុំរមនា ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី ឱ្យទៅឈ្មោះ [redacted]សាវ៉ាន់។ ដីដែលខ្លួនលក់ឱ្យទៅឈ្មោះ [redacted] សាវ៉ាន់ គឺមានព្រំដីជាប់ព្រំដីរបស់ឈ្មោះ [redacted]យឿន ពិតមែន មិនមែនជាដីជាន់គ្នានោះទេ។ ចំពោះសេចក្តីបញ្ជាក់របស់អ្នកមានព្រំប្រទល់ដីជាប់គ្នា គឺខ្លួនជាអ្នកយកទៅឱ្យឈ្មោះ [redacted] យឿន ផ្តិតមេដៃ ប៉ុន្តែឈ្មោះ[redacted]យឿន បានឆ្លើយ គាត់មិនមានសិទ្ធិទៀតទេ ពីព្រោះគាត់បានប្រគល់ដីឱ្យទៅកូនអស់ហើយ។ ពេលនោះឈ្មោះ[redacted] យឿន បានប្រាប់ខ្លួនឱ្យទៅជួបកូនគាត់ឈ្មោះ [redacted] សាវ៉ន និងឈ្មោះ[redacted] សុផល។ នៅពេលខ្លួនបានទៅជួបឈ្មោះ[redacted]សាវ៉ន និងឈ្មោះ[redacted] សុផល ហើយប្រគល់សេចក្តីបញ្ជាក់របស់អ្នកមានព្រំប្រទល់ដីជាប់គ្នា ភ្លាមនោះឈ្មោះ[redacted]សាវ៉ន និងឈ្មោះ [redacted] សុផល ក៏ផ្តិតមេដៃតែម្តង រួចខ្លួនក៏ត្រឡប់មកវិញ ហើយយកសេចក្តីបញ្ជាក់របស់អ្នកមានព្រំប្រទល់ដីជាប់គ្នាឱ្យឈ្មោះ ឆឹយ សុធី។

-សាក្សីឈ្មោះ[redacted]សុធី បានឆ្លើយបំភ្លឺថា: កាលពីអំឡុងឆ្នាំ២០០៧ ឈ្មោះ[redacted]សាវ៉ាន់ បានឱ្យខ្លួនមកទំនាក់ទំនងទិញដីពីឈ្មោះ [redacted]សុផាត ដែលមានទំហំប្រហែលប្រាំមួយ ទៅប្រាំពីរហិកតា ស្ថិតនៅភូមិពូលូង ឃុំ



Scanned with CamScanner

រមនា ស្រុកសែនមនោរម្យ ខេត្តមណ្ឌលគិរី ។ បន្ទាប់មកឈ្មោះ ឌុច សុផាត ក៏បានចុះទៅបង្ហាញទីតាំងព្រំដី និងធ្វើការវាស់វែង ឃើញថា ដីមានទំហំប្រាំមួយហិកតាជាង។ ក្រោយមកខ្លួន និងឈ្មោះ [redacted] សុផាត បាននាំគ្នាមកជួបលោក [redacted] សារ៉ាន់ ដើម្បីកក់ប្រាក់ ហើយចំពោះលិខិតទិញលក់ដី និងលិខិតផ្ទេរសិទ្ធិ គឺឈ្មោះ [redacted] សុផាត ជាអ្នករត់ការធ្វើ។ ក្រោយពេលព្រមព្រៀងទិញលក់ដីហើយ លោក [redacted] សារ៉ាន់ បានជួលគ្រឿងចក្រឈូសឆាយដីទំហំបួនម៉ែត្រវាប់តាមព្រំដីដែលមានបង្គោលរបងព្រំរវាងឈ្មោះ [redacted] សុផាត និងឈ្មោះ [redacted] យឿន ហើយក៏មិនមានអ្នកហាមឃាត់ដែរ។

-សាក្សីឈ្មោះ [redacted] **សុខា** បានឆ្លើយបំភ្លឺថា: ដីទំនាស់នេះ ក្នុងឆ្នាំ១៩៩៥ ឈ្មោះ [redacted] យឿន បានឱ្យខ្លួនជួយកាប់ឆ្ការដី និងរើសដុំថ្ម នៅលើដីនេះ។ ពេលខ្លួនទៅកាប់ឆ្ការដីនោះ ឈ្មោះ [redacted] យឿន មិនបានប្រាប់ខ្លួនថាដីនេះមានលិខិតស្នាម ឬ អត់នោះទេ។ ហើយនៅថ្ងៃកើតហេតុ ខ្លួន មិនបានឃើញឈ្មោះ [redacted] សុផល នៅកន្លែងដីទំនាស់ទេ គឺឃើញតែបងប្អូនគាត់។

-សាក្សីឈ្មោះ [redacted] **សុណាវ** បានឆ្លើយបំភ្លឺថា: ពេលខ្លួនទៅកាប់ឆ្ការដីឱ្យឈ្មោះ [redacted] យឿន ឃើញនៅលើដីចំការនោះ មានចិញ្ចឹមគោ មានដំណាំផ្សេងៗដែលដំណាខ្លះមានផ្លែ ហើយនៅជាប់ដីនោះ គ្មានចំការរបស់អ្នកផ្សេងទៀតទេ។ ចំពោះរឿងហេតុ ទាក់ទងនឹង ហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិតនោះ ខ្លួនមិនបានដឹងទេ។

-សាក្សីឈ្មោះ [redacted] **ញ៉ិត** បានបំភ្លឺថា: ឈ្មោះ [redacted] យឿន ធ្លាប់ឱ្យខ្លួនទៅជួយកាប់ឆ្ការដីរបស់គាត់ ពេលនោះឃើញនៅលើដីចំការនោះ មានចិញ្ចឹមគោ មានដំណាំផ្សេងៗដែលដំណាខ្លះមានផ្លែ ហើយនៅជាប់ដីនោះ គ្មានចំការរបស់អ្នកផ្សេងទៀតទេ។ ចំពោះរឿងហេតុ ទាក់ទងនឹង ហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិតនោះ ខ្លួនមិនបានដឹងទេ។

-សាក្សីឈ្មោះ [redacted] **បូរ៉េត** បានបំភ្លឺថា: ខ្លួនត្រូវជាប្អូនថ្លៃរបស់ឈ្មោះ [redacted] យឿន ហើយដាំដំណាំផ្សេងនៅលើចំការរបស់គាត់។ ចំពោះរឿងហេតុ ទាក់ទងនឹង ហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិតនោះ ខ្លួនមិនបានដឹងទេ។

-សាក្សីឈ្មោះ [redacted] កំពី បានបំភ្លឺថា: ដីទំនាស់នេះ ឈ្មោះ [redacted] យឿន បានដាំដើមកំភេរ ចិញ្ចឹមជ្រូក មាន់ គោ។ ចំពោះរឿងហេតុ ទាក់ទងនឹង ហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិតនោះ ខ្លួនមិនបានដឹងទេ។

-សាក្សីឈ្មោះ [redacted] **ទន់** បានឆ្លើយបំភ្លឺថា: ខ្លួនគ្រាន់តែបានដឹងថាដីទំនាស់នេះ ធ្លាប់មានចិញ្ចឹមគោ។ ហើយកាលពីមុន មានឈ្មោះ អ៊ែល ចិញ្ចឹមគោនៅជាប់ដីនេះដែរ។ ចំពោះរឿងហេតុ ទាក់ទងនឹង ហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិតនោះ ខ្លួនមិនបានដឹងទេ។

-សាក្សីឈ្មោះ [redacted] ទិច បានឆ្លើយបំភ្លឺថា: ឈ្មោះ [redacted] យឿន ធ្លាប់ឱ្យខ្លួនទៅជួយកាប់ឆ្ការដីរបស់គាត់ ពេលនោះឃើញនៅលើដីចំការនោះ មានចិញ្ចឹមគោ មានាដំណាំផ្សេងៗដែលដំណាខ្លះមានផ្លែ ហើយនៅជាប់ដីនោះ គ្មានចំការរបស់អ្នកផ្សេងទៀតទេ។ ចំពោះរឿងហេតុ ទាក់ទងនឹង ហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិតនោះ ខ្លួនមិនបានដឹងទេ។



Scanned with CamScanner

-តំណាងអយ្យការធ្វើសេចក្ដីសន្និដ្ឋាន: ក្រោយពីបានបញ្ចប់កិច្ចពិភាក្សាវែញដោល ក្នុងនាមជាតំណាងអយ្យការ ដោយពិនិត្យភស្តុតាងជាឯកសារ របស់ដើមបណ្ដឹងដែលដាក់ចូលមកតុលាការ មានលិខិតផ្ទេរសិទ្ធិត្រឹមត្រូវ ចំណែកឯជនជាប់ចោទពុំមានលិខិតទាក់ទងនឹងកម្មសិទ្ធិនោះទេ និងយោងតាមបញ្ជីសម្រង់វត្តមានប្រចាំថ្ងៃរបស់មន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យា ឃើញថាជនជាប់ចោទឈ្មោះ [redacted] **សុផល** នៅថ្ងៃកើតហេតុពិតជាបាននៅកន្លែងធ្វើការពិតមែន។ ហេតុដូច្នេះ តំណាងអយ្យការសូមរក្សាការចោទប្រកាន់ និងប្ដឹងសុំឱ្យតុលាការ ផ្ដន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] **សាវ៉ន** ,ឈ្មោះ [redacted] **រតនា** និងឈ្មោះ [redacted] **ឡូន** ពីបទ: **ហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត** ប្រព្រឹត្តនៅចំណុចភូមិពូលូង សង្កាត់រមនា ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី កាលពីអំឡុងខែមិថុនា ឆ្នាំ២០២០ បទល្មើសផ្ដន្ទាទោសតាមមាត្រា **២៥៨** និងមាត្រា **២៥៣** នៃច្បាប់ភូមិបាល និងស្នើសុំតុលាការ ពិចារណាឱ្យជនជាប់ចោទឈ្មោះ [redacted] **សុផល** រួចផុតពីបទចោទប្រកាន់ **ហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត** ប្រព្រឹត្តនៅចំណុចភូមិពូលូង សង្កាត់រមនា ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី កាលពីអំឡុងខែមិថុនា ឆ្នាំ២០២០។

-មេធាវីការពារសិទ្ធិឱ្យដើមបណ្ដឹងរដ្ឋប្បវេណី ធ្វើសេចក្ដីសន្និដ្ឋានថា៖ ក្រោយពីបានស្ដាប់អង្គសវនាការដូចតុលាការបានជ្រាបហើយថា កូនក្ដីរបស់ខ្ញុំបាទ កាលពីថ្ងៃទី០១ ខែសីហា ឆ្នាំ២០០៧ បានទិញដីដែលមាន ទទឹងទំហំ ១៩៣ម៉ែត្រ បណ្ដោយ ៣៥០ ម៉ែត្រ ស្ថិតនៅភូមិពូលូង ឃុំរមនា ស្រុកសែនមនោរម្យ ខេត្តមណ្ឌលគិរី ពីឈ្មោះ [redacted] សុជាត និងប្រពន្ធឈ្មោះ [redacted] ភ៉ានី ដែលមានលិខិតផ្ទេរសិទ្ធិកាន់កាប់លេខ **១៩៨/០៧** ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០៧ ចេញដោយមេឃុំរមនា ព្រមទាំងមានស្នាមម្រាមដៃអ្នកជាប់ព្រំផងដែរ។ លុះឆ្នាំ២០១៤ កូនក្ដីខ្ញុំបាទ បានឈូសឆាយដីនោះធ្វើផ្លូវ ប៉ុន្តែគ្មានអ្នកណាចេញមុខមកហាមឃាត់ ឬ ប្ដឹងផ្ដល់ដែរ។ លុះឆ្នាំ២០១៧ កូនក្ដីខ្ញុំបាទ បានឈូសឆាយដី និងចាក់ដើងតាងថ្មបន្ថែមតាមជ្រុងនៃព្រំដី ក៏នៅគ្មាននរណាម្នាក់ចេញមុខហាមឃាត់ ឬប្ដឹងផ្ដល់ដដែល ទើបតែនៅថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២០ កូនក្ដីខ្ញុំបាទបានយកគ្រឿងចក្រទៅឈូសឆាយដាក់បង្គោលរបងថ្មបន្ថែម ស្រាប់តែឈ្មោះ [redacted] សាវ៉ន ឈ្មោះ [redacted] សុផល ,ឈ្មោះ [redacted] ឡូន ,ឈ្មោះ [redacted] រតនា និងបក្ខពួកបានស្រែកឡូឡា រារាំងដេកដួលមុខគ្រឿងចក្រ ស្រែកជេរប្រមាថដោយពាក្យអសុរស មកលើកូនក្ដីខ្ញុំ និងបានវាយបំផ្លាញបង្គោលរបងថ្មថែមទៀត។ លុះដល់ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០ ឈ្មោះ [redacted] សាវ៉ន ,ឈ្មោះ [redacted] សុផល ,ឈ្មោះ [redacted] ឡូន ,ឈ្មោះ [redacted] រតនា និងបក្ខពួក បានយកគ្រឿងចក្រមកឈូសឆាយលើដីរបស់កូនក្ដីខ្ញុំ និងបំផ្លាញរបងថ្មសរុបទាំងពីរលើកអស់ចំនួន ៣៦០ ដើម ហើយបានជេរប្រមាថដល់កូនក្ដីខ្ញុំបាទទៀត។ ដោយផ្អែកលើភស្តុតាងរួមមាន ពាក្យសុំកាន់កាប់ប្រើប្រាស់ដីធ្លីលេខ ១២៣/០៧ ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០០៧ , សេចក្ដីបញ្ជាក់របស់អ្នកមានព្រំប្រទល់ដីជាប់គ្នា ១២៣/០៧ ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០០៧ និងលិខិតផ្ទេរសិទ្ធិកាន់កាប់លេខ ១៩៨/០៧ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០៧, ចម្លើយសាក្សីឈ្មោះ ឃន់ អូន,ឈ្មោះ ផែង សូរិយា , ឈ្មោះ [redacted] ប៊ុក,ឈ្មោះ [redacted] ទូច, កំណត់ហេតុស្ដីពីការសួរបំភ្លឺចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២០,លិខិតលេខ ០៥៤/២០ របក ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២០ បានបញ្ជាក់ថា: ក្នុងឆ្នាំ២០០៧ កូនក្ដីខ្ញុំបាទពិតជាបានទិញដីពីឈ្មោះ [redacted] សុជាត និងប្រពន្ធឈ្មោះ [redacted] ភ៉ានី និងបានឈូសឆាយជាច្រើនលើកច្រើនសារ និងដាំបង្គោលគ្រាក់ ដាំ

បង្គោលថ្ម ចាក់ជើងតាងជាដើម ពុំមាននរណាមកប្តឹងជំទាស់ដែរ ទើបតែនៅថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២០ ពេលកូនក្តីខ្លួនកំពុងសំអាតដីជាធម្មតា ស្រាប់តែមានកូនៗរបស់លោក ចាន់ យឿន មករារាំង ហាមឃាត់ និងរំខានដល់ការអភិវឌ្ឍរបស់កូនក្តីខ្ញុំបាទ និងបានដេរប្រមាថ និងបំផ្លិចបំផ្លាញរបងថ្មរបស់កូនក្តីខ្ញុំបាទ។ ចំពោះចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted]សាវ័ន ,ឈ្មោះ [redacted] សុផល ,ឈ្មោះ [redacted]ឡុន ,ឈ្មោះ [redacted]រតនា លើកឡើងប្រហាក់ប្រហែលគ្នាថា ដីដែលកូនក្តីខ្ញុំកាន់កាប់នេះជារបស់ឪពុកខ្លួនឈ្មោះ [redacted] យឿន នោះគឺជាការលើកឡើងកុហកតុលាការ ព្រោះពួកគាត់គ្មានឯកសារផ្លូវច្បាប់ណាមួយដើម្បីបញ្ជាក់ការលើកឡើងនោះទេ។ ចេតនាដែលស្តែងចេញពីសកម្មភាពរារាំង ដេរប្រមាថ និងរំលោភកាន់កាប់ដីរបស់កូនក្តីខ្ញុំ ដែលជាអ្នកកាន់កាប់អចលនវត្ថុដោយសន្តិភាពនៃទ្រព្យដែលមិនទាន់មានប្លង់សុរិយោដី គឺជាការប៉ះពាល់កម្មសិទ្ធិ និងសិទ្ធិស្របច្បាប់ផ្សេងទៀតលើអចលនវត្ថុ។ ជាងនេះទៅទៀត ជនជាប់ចោទបានយកគ្រឿងចក្រ ធ្វើការឈូសឆាយដី ដែលមានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីដែលទទួលស្គាល់ដោយអាជ្ញាធរ ខណៈពេលដែលជនជាប់ចោទពុំមានលិខិតបញ្ជាក់ពីកម្មសិទ្ធិអ្វីទាំងអស់ គឺជាបទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៤៨ និងមាត្រា ២៥៣ នៃច្បាប់ភូមិបាល។ អំពើរបស់ជនជាប់ចោទបានបំផ្លិចបំផ្លាញរបងថ្មរបស់កូនក្តីខ្ញុំអស់ចំនួន ៣៦០ ដើម ដែលក្នុង០១ដើមទាំងឈ្នួលដាំ និងបង្គោល មានតម្លៃ USD ៧,២០ (ប្រាំពីរដុល្លារនិងម្ភៃសេន) សរុបរួមគឺ USD ២៧៩០ (ពីរពាន់ប្រាំពីររយកៅសិបដុល្លារអាមេរិក) និងធ្វើឱ្យកូនក្តីខ្ញុំអាក់ខានមិនអាចចូលកាន់កាប់ ខាតពេលវេលា សេវាកម្មជួលមេធាវីការពារក្តី។ ហេតុដូច្នេះ ដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសនេះកុំឱ្យកើតមានបន្តទៀតមកលើកូនក្តីខ្ញុំបាទ ក្នុងនាមជាមេធាវីតំណាងការពារក្តី និងតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណី សូមសំណូមពរ តុលាការមេត្តាពិចារណា និងសម្រេចផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] រតនា ,ឈ្មោះ [redacted]សាវ័ន ,ឈ្មោះ [redacted] ឡុន និងឈ្មោះ [redacted] សុផល ឱ្យបានធ្ងន់ធ្ងរ និងស្នើសុំតុលាការបង្គាប់ឱ្យជនជាប់ចោទខាងលើរួមគ្នាសងសំណងការខូចខាត និងសំណងជំងឺចិត្តមកកូនក្តីខ្ញុំចំនួន ២០,០០០ (ពីរម៉ឺនដុល្លារអាមេរិក)។

-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted]សុផល ធ្វើសេចក្តីសន្និដ្ឋានថា៖ ក្រោយពីបានស្តាប់អង្គសវនាការ ដូចតុលាការ បានជ្រាបហើយថា នៅថ្ងៃកើតហេតុថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២០ លោកស្រី [redacted] សុផល មិនស្ថិតនៅកន្លែងកើតហេតុ ដោយមានភស្តុតាងមានបញ្ជីសម្រង់វត្តមានប្រចាំថ្ងៃរបស់មន្ត្រីរាជការ និងសាក្សីលោក ទេព សុខា បញ្ជាក់។ គ្មានធាតុផ្សំនៃបទល្មើសដែលអាចបញ្ជាក់ថា លោកស្រី [redacted]សុផល មានពិរុទ្ធ ពោលគឺ លោកស្រី [redacted] សុផល មិនមែនជាម្ចាស់ដីនៃព្រំប្រទល់ខាងកើត និងមិនមានចេតនាប្រើហិង្សាលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត ឡើយ។ តាមការអះអាង របស់សាក្សីគឺឈ្មោះ [redacted] សុធី និងសាក្សីលោក [redacted]បុផាត មិនបានអញ្ជើញអ្នកដែលមានព្រំប្រទល់ដីជាប់គ្នា ដើម្បីវាស់វែងត្រឹមត្រូវឡើយ ហើយភាគីព្រំខាងកើត ជាម្ចាស់ដីពុំបានអញ្ជើញឱ្យចូលវាស់វែងក្នុងពេលធ្វើនីតិវិធីផ្ទេរកម្មសិទ្ធិ ដោយពួកគាត់បានវាស់វែង តែរវាងអ្នកលក់ និងអ្នកទិញ មិនបានចូលរួមពីអ្នកដែលមានព្រំប្រទល់ដីជាប់គ្នាឡើយ។ លោកស្រី ចាន់ សុផល មិនបានផ្តិតមេដៃលើលិខិតកាន់កាប់ និងមិនបានផ្តិតមេដៃជាអ្នកមានព្រំប្រទល់ដីជាប់គ្នាឡើយ អង្គហេតុនិងពេលវេលាមិនស៊ីចង្វាក់គ្នា ហើយលោកស្រី [redacted]សុផល ក៏មិនមែនជាម្ចាស់សិទ្ធិក្នុងការផ្តិតស្នាមមេដៃជាអ្នកមានព្រំប្រទល់ដីជាប់គ្នាឡើយ។ ទំនាស់



Scanned with CamScanner

កើតឡើងពីការមិនបានបញ្ជាក់ព្រំប្រទល់ដីអ្នកដែលមានព្រំប្រទល់ដីជាប់គ្នា និងមិនមែនជាអង្គហេតុដែលនាំឱ្យមានការចោទប្រកាន់តាមមាត្រា ២៤៨ និងមាត្រា ២៥៣ នៃច្បាប់ភូមិបាល ឆ្នាំ២០០១ ឡើយ។ ឯកសារផ្ទេរសិទ្ធិ និងកាន់កាប់ដីរបស់ឈ្មោះ [redacted] សារ៉ាន់ មានភាពមិនប្រក្រតី និងមិនមានការបញ្ជាក់ច្បាស់លាស់អំពីអ្នកដែលមានព្រំប្រទល់ដីជាប់គ្នា។ យោងតាមមាត្រា ៤ នៃក្រមព្រហ្មទណ្ឌ ពុំមានបទល្មើសទេ ប្រសិនបើគ្មានចេតនាប្រព្រឹត្ត។ ធាតុអត្តនោម័ត ពេលវេលាមិនស៊ីចង្វាក់គ្នា ខណៈពេលមានការវែកញែកកន្លែងកើតហេតុ នាថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២០ នៅលើដីដែលមានទំនាស់ព្រំដីនោះ គឺ លោកស្រី [redacted] សុផល មិនស្ថិតនៅកន្លែងកើតហេតុឡើយ។ បានស្តាប់ការសន្និដ្ឋានរបស់ព្រះរាជអាជ្ញា ស្នើសុំតុលាការលើកលែងការចោទមកលើជនជាប់ចោទឈ្មោះ ចាន់ សុផល។ ដូចនេះ ក្នុងនាមខ្ញុំជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted]សុផល សូមស្នើសុំតុលាការមេត្តា លើកលែងការចោទប្រកាន់ចំពោះលោកស្រី ចាន់ សុផល និងបងប្អូន ព្រោះលោកស្រី [redacted] សុផល គ្មានចេតនាប្រព្រឹត្តបទល្មើស ព្រោះពេលវេលាដែលបានអះអាងក្នុងពាក្យបណ្តឹងមិនស៊ីចង្វាក់គ្នា គឺលោកស្រី[redacted]សុផល មិនស្ថិតនៅកន្លែងកើតហេតុ និងសូមតុលាការកុំទទួលស្គាល់លើលិខិតផ្ទេរសិទ្ធិ ដែលធ្វើឡើងពុំត្រឹមត្រូវ និងខុសច្បាប់ ដោយហេតុថា ការផ្តិតមេដៃពុំបានធ្វើឡើងដោយម្ចាស់ដីពិតប្រាកដ ហើយគ្មានការព្រមព្រៀងត្រឹមត្រូវពីអ្នកដែលមានព្រំប្រទល់ដីជាប់គ្នា និងគ្មានការវាស់វែងដោយអ្នកជំនាញសុរិយោដី ដែលជាហេតុនាំអោយមានភាពអយុត្តិធម៌ចំពោះលោកស្រី[redacted]សុផល។

-សម្តីចុងក្រោយរបស់ជនជាប់ឈ្មោះ [redacted] **សុផល** ថា: សុំតុលាការជួយរកយុត្តិធម៌ឱ្យខ្លួនផង សុំបង្វែរសំណុំរឿងទៅគណៈកម្មការដោះស្រាយវិវាទ និងសុំឱ្យតុលាការមេត្តាលើកលែងចោទប្រកាន់ដល់រូបខ្លួនផង។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទឈ្មោះ [redacted] **សុផល** ,អំណានចម្លើយជនជាប់ចោទឈ្មោះ [redacted] **រតនា** ,[redacted] **សាវិន** [redacted] **ឡួន** ។

-ក្រោយពីបានស្តាប់អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]**សារ៉ាន់** ។

-ក្រោយពីបានស្តាប់អំណានចម្លើយសាក្សីឈ្មោះ [redacted] **អួន**,[redacted] **សូរិយា** ,ចម្លើយសាក្សីឈ្មោះ [redacted] **ខួច** ,[redacted] **ប៊ុក** [redacted]**សុជាត** ,[redacted] **សុធី** ,[redacted] **សុខា**, [redacted] **សុណារ** ,[redacted] **ញឹក** , [redacted] **បូរ៉េត** , [redacted] **កំពី** [redacted] **ទង់** , [redacted]**ចេ**។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការប្តឹងសុំ ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានមេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណី។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានមេធាវីការពារសិទ្ធិរបស់ជនជាប់ចោទឈ្មោះ [redacted] **សុផល** ។

-ក្រោយពីបានស្តាប់សម្តីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] **សុផល** ។

-ក្រោយពីបានពិនិត្យភស្តុតាង និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ ។

## សំអាងហេតុ

## តុលាការយល់ឃើញថា

១.កាលពីអំឡុងខែមិថុនា ឆ្នាំ២០២០ នៅចំណុចភូមិពូលូង សង្កាត់រមនា ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី មានករណីហិង្សាទៅលើអ្នកកាន់កាប់ដោយសុចរិត បានកើតឡើងប្រព្រឹត្តដោយជនជាប់ចោទឈ្មោះ [redacted] រតនា ភេទប្រុស ,ឈ្មោះ [redacted]ាវិន ភេទស្រី ,ឈ្មោះ [redacted]ឡួន ភេទប្រុស ,ឈ្មោះ [redacted] សុផល ភេទស្រី និងបក្ខពួក



Scanned with CamScanner

បានធ្វើសកម្មភាពដកបំផ្លាញបង្គោលរបងថ្មព្រំដី និងយកគ្រឿងចក្រមកឈូសឆាយដីរបស់ឈ្មោះ [redacted] សារ៉ាន់ ដែលមានលិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លីលេខ ១៩៨/០៧ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០៧ ទទួលស្គាល់ដោយអាជ្ញាធរភូមិឃុំ ទាំងដែលជនជាប់ចោទទាំងបួននាក់ខាងលើ ពុំមានឯកសារពាក់ព័ន្ធអ្វីទាំងអស់។

២.តាមអំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] រតនា បានសារភាពថាៈ ខ្លួនសុំបដិសេធចោលទាំងស្រុងលើពាក្យបណ្តឹងរបស់ឈ្មោះ [redacted] សារ៉ាន់ ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២០។ ដីទំនាស់ខាងលើមានទីតាំងដីស្ថិតនៅភូមិពូលូង សង្កាត់រមនា ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី មានទំហំ៣៧ហិកតា គឺជាដីដែលឪពុករបស់ខ្លួនឈ្មោះ [redacted] យឿង និងម្តាយបានកាន់កាប់ប្រើប្រាស់អាស្រ័យផលតាំងពីឆ្នាំ១៩៩៤ មកម្ល៉េះ ដោយគាត់បាននិយាយប្រាប់ខ្លួនថា គាត់មានឯកសារគ្រប់គ្រាន់ដែលទទួលស្គាល់ដោយអាជ្ញាធរមានសមត្ថកិច្ច។ តាំងពីពេលកាន់កាប់គ្រួសាររបស់ខ្លួនបានបង្កបង្កើនផលដូចជា ដាំកាហ្វេ ធុរេន ប័រ សាម៉ាវ សម្រាប់លក់។ កន្លងមកអំឡុងឆ្នាំ២០០៣ មានការឈូសឆាយលើកទី១ ខ្លួន និងបងឈ្មោះ [redacted] សាវ៉ន ក៏បានធ្វើការហាមឃាត់ពួកគេ (មិនស្គាល់ថា នរណាជាអ្នកឈូសឆាយ) មិនឱ្យធ្វើការឈូសឆាយ។ រហូតដល់ថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២០ ក៏មានការឈូស ឆាយជាលើកទី២ ព្រមទាំបានដកបង្គោលរបងទើបខ្លួនដឹងថាឈ្មោះ [redacted] សារ៉ាន់ ជាអ្នកបញ្ជាកម្មករឱ្យមកធ្វើការឈូសឆាយលើដីចំការចាស់របស់ឪពុកម្តាយខ្លួន ស្ថិតនៅភូមិពូលូង សង្កាត់រមនា ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី ពេលនោះខ្លួននិងបងរបស់ខ្លួនឈ្មោះ [redacted] សាវ៉ន ,ឈ្មោះ [redacted] ឡុន បានធ្វើការហាមឃាត់ ពួកគេម្តងទៀត។ ក្រោយមកពួកខ្លួនក៏បានស្នើសុំឱ្យលោកអភិបាលក្រុង ជួយអន្តរាគមន៍ផ្អាកសកម្មភាពឈូសឆាយសិនរង់ចាំការដោះស្រាយនៅសាលាក្រុង ខណៈពេលនោះលោក [redacted] ចាន់ឌី និងកម្លាំងចម្រុះបានចុះទៅហាមឃាត់។ ខ្លួននឹងបងប្អូនរបស់ខ្លួនពុំបានជេរប្រមាថទៅលើឈ្មោះ [redacted] សារ៉ាន់ ឬ ដកបង្គោលរបងនោះទេ។ នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០ លោក [redacted] វិបុល បានទាក់ទងមកបងប្អូនរបស់ខ្លួនឱ្យទៅសាលាក្រុងដើម្បីដោះស្រាយ បន្ទាប់មកពួកខ្លួន ក៏បានទៅសាលាក្រុងតាមការអញ្ជើញរបស់លោកអភិបាល ប៉ុន្តែពុំមានភាគីណាមួយចូលរួមដោះស្រាយឡើយ រហូតមកដល់បច្ចុប្បន្ន។

៣.តាមអំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សាវ៉ន បានសារភាពថាៈ ចំការជារបស់ឪពុកឈ្មោះ [redacted] យឿន និងម្តាយរបស់ខ្លួនឈ្មោះ [redacted] សូរិយា ដែលមានទីតាំងស្ថិតនៅភូមិពូលូង សង្កាត់រមនា ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី ពិតមែន ហើយលិខិតកាន់កាប់ដីធ្លីគឺមិននៅនឹងខ្លួនទេ គឺនៅនឹងឪពុករបស់ខ្លួន ដីចំការនោះមានទំហំ ៣៧ហិកតា។ លុះដល់ថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២០ ខ្លួនក៏បានជិះម៉ូតូទៅទីតាំងដីដែលមានជម្លោះ និងបានជួបជាមួយបងប្រុសរបស់ខ្លួនឈ្មោះ [redacted] ឡុន និងប្អូនប្រុសរបស់ខ្លួន ឈ្មោះ [redacted] រតនា និងបានជួបជាមួយអ្នកកាសែតចំនួន០២ នាក់ តែខ្លួនមិនស្គាល់ឈ្មោះទេ និងមិនបានឃើញឈ្មោះ [redacted] សារ៉ាន់ នៅទីនោះទេ ប៉ុន្តែបានឃើញគេបើកគ្រឿងចក្រចំនួន០២គ្រឿង កំពុងឈូសឆាយលើដីចំការឪពុករបស់ខ្លួន។ ស្របពេលនោះខ្លួនក៏បានសុំឱ្យអ្នកបើកគ្រឿងចក្រ នោះឈប់ឈូសឆាយដី តែគេមិនព្រមឈប់ឈូសឆាយនោះទេ។ ហើយពេលនោះខ្លួនក៏មិនបានជេរ និងមិនបានវាយបង្គោលរបងថ្មរបស់ឈ្មោះ [redacted] សារ៉ាន់ នោះដែរ ព្រោះខ្លួនមិនដែលស្គាល់ឈ្មោះ [redacted] សារ៉ាន់ និងឈ្មោះ [redacted] សុជាត នោះឡើយ។ នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០ ខ្លួន និងបងប្អូនរបស់ខ្លួន បានយកគ្រឿងចក្រទៅឈូសឆាយនៅលើដីចំការរបស់ឪពុកម្តាយរបស់ខ្លួន ដើម្បីឱ្យដឹងព្រំប្រទល់ដីឱ្យបានច្បាស់លាស់។ ចំពោះស្នាមមេដៃ

ដែលបានដាក់ឈ្មោះខ្លួនលើលិខិតសេចក្តីបញ្ជាក់របស់អ្នកជាប់ព្រំប្រទល់ដីជាប់គ្នាចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០០៧ គឺមិនមែនជាស្នាមមេដៃរបស់ខ្លួនទេ ព្រោះកាលនោះខ្លួនមិនបានផ្តិតមេដៃឲ្យឈ្មោះ [redacted] សុជាត ហើយ ខ្លួនក៏ពុំដែលស្គាល់ឈ្មោះ ឌុច សុជាត ដែរ។ ខ្លួនពុំបានបញ្ជាឲ្យអ្នកណាទៅប្រើអំពើហិង្សាលើជនរងគ្រោះណាម្នាក់ឡើយ។

៤.តាមអំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **ឡូន** បានសារភាពថា៖ ខ្លួនសុំបដិសេធចោលទាំងស្រុងលើពាក្យបណ្តឹងរបស់ឈ្មោះ [redacted]**សាវ៉ាន់** ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២០ ដោយហេតុថា ខ្លួនពុំបានប្រព្រឹត្តដូចការចោទប្រកាន់។ ដីចំការជារបស់ឪពុកឈ្មោះ [redacted] **យឿន** និងម្តាយឈ្មោះ [redacted] **សូរិយា** ដែលមានទីតាំងស្ថិតនៅភូមិពូលូង សង្កាត់រមនា ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី ពិតមែន ដោយពួកគាត់បានកាន់កាប់តាំងពីឆ្នាំ១៩៩៤ មកម្ល៉េះ។ ចំពោះលិខិតកាន់កាប់ដីធ្លីខ្លួនមិនដឹងថា មាន ឬអត់នោះទេ។ ដីចំការខាងលើនេះមានទំហំ ៣៧ ហិកតា។ អំឡុងពេលកាន់កាប់នោះ គ្រួសាររបស់ខ្លួនក៏បានដាំដំណាំបង្កបង្កើតផល ដូចជា ដើម កាហ្វេ ធុរេន សាម៉ាវ និងចិញ្ចឹមមាន់ គោ ទុកសម្រាប់លក់។ នៅអំឡុងឆ្នាំ២០០៣ អ៊ុំស្រីរបស់ខ្លួនឈ្មោះ មោង ប៉ាក់ បានប្រាប់ខ្លួនថាមានការឈូសឆាយដីរបស់គ្រួសារខ្លួន ក្នុងនោះ មានឈ្មោះ [redacted] **វិបុល** និងពីរនាក់ទៀត មិនស្គាល់ឈ្មោះទេ។ រហូតដល់ថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២០ ប្អូនប្រុសរបស់ខ្លួនបានខលហៅខ្លួន ឲ្យទៅមើលគេឈូសឆាយដី និងដកបង្គោលរបង នៅពេលដែលខ្លួនទៅដល់ឃើញ មានគ្រឿងចក្រចំនួន០២គ្រឿង និងមានម៉ាស៊ីនខ្វង់ដីមួយគ្រឿងកំពុងតែធ្វើសកម្មភាព ឈូសឆាយដីខាងលើ និងមានកម្មករប្រហែលជា ១០ នាក់ ព្រមទាំងមនុស្សផ្សេងទៀត ខ្លួនស្គាល់តែឈ្មោះ [redacted]**រិយា** តែម្នាក់ប៉ុណ្ណោះ។ ពេលនោះខ្លួន និងបងប្អូនពុំបានជេរ ប្រមាថទៅលើបុគ្គលឈ្មោះ [redacted] **សាវ៉ាន់** ឬបំផ្លិចបំផ្លាញបង្គោលរបងទេ។ ក្រោយមកនៅថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២០ បងប្អូនរបស់ខ្លួនព្រមទាំងខ្លួនក៏បានឲ្យប្អូនស្រីឈ្មោះ [redacted] **សីហៈម៉ានី** ទៅសាលាក្រុងដើម្បីសុំកិច្ចអន្តរាគមន៍ ដើម្បីបញ្ឈប់ការឈូសឆាយ និងដោះស្រាយដីទំនាស់ខាងលើ។ ខ្លួនពុំបានបញ្ជាឲ្យអ្នកណាទៅប្រើអំពើហិង្សាលើជនរងគ្រោះណាម្នាក់ឡើយ។

៥.តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **សុផល** បានសារភាពថា៖ ចំពោះពាក្យបណ្តឹងដែលឈ្មោះ [redacted]**សាវ៉ាន់** ប្តឹងខ្លួនពីបទ ប៉ះពាល់កម្មសិទ្ធិឯកជន និងប្រើអំពើហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២០ នោះ គឺខ្លួន សូមបដិសេធ ព្រោះខ្លួនមិនបានប្រព្រឹត្តដូចដែលឈ្មោ[redacted]**សាវ៉ាន់** ប្តឹងនោះទេ។ ខ្លួនមានដីចំការរបស់ឪពុក ឈ្មោះ [redacted] **យឿន** និងម្តាយខ្លួនឈ្មោះ [redacted] **សូរិយា** ដែលមានទីតាំងស្ថិតនៅភូមិពូលូង សង្កាត់រមនា ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី ពិតមែន។ ហើយដីនោះមានលិខិតកាន់កាប់ ឬអត់នោះគឺខ្លួនពុំបានដឹងនោះទេ។ ហើយកាលនោះ ខ្លួនបានដឹងថាដីឪពុកម្តាយរបស់ខ្លួន ខាងកើតជាប់នឹងភ្នំ ,ខាងលិចទល់អូរ ,ខាងត្បូងទល់អូរតូច និងខាងជើង ជាប់នឹងច្រកគរ ហើយដីរបស់ឪពុកម្តាយខ្លួនមានទំហំ ៣៧ ហិកតា។ កាលពីថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២០ គឺខ្លួនមិនបាននៅក្នុងហេតុការណ៍ទៅហាមឃាត់គ្រឿងចក្ររបស់ឈ្មោះ [redacted] **សាវ៉ាន់** ដែលបានឈូសឆាយដីរបស់ ឪពុកម្តាយរបស់ខ្លួននោះទេ។ ចំពោះស្នាមមេដៃដែលបានដាក់ឈ្មោះខ្លួន លើលិខិតសេចក្តីបញ្ជាក់របស់អ្នកមានព្រំប្រទល់ដីជាប់គ្នា ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០០៧ នោះ គឺមិនមែនជាស្នាមមេដៃរបស់ខ្លួននោះទេ ព្រោះកាលនោះ ខ្លួនមិនបានផ្តិតមេដៃទៅឲ្យឈ្មោះ[redacted]**សុជាត** នោះទេ។ ប៉ុន្តែកាលនោះគឺឈ្មោះ [redacted] **សុជាត** បានទៅជួបឪពុករបស់ខ្លួន ពេលនោះឪពុករបស់ខ្លួនបានឲ្យឈ្មោះ [redacted] **សុជាត** ទៅជួបជាមួយប្តីរបស់ខ្លួនឈ្មោះ



Scanned with CamScanner

[redacted] **ជ្រើង** ហើយនៅពេលនោះប្ដីរបស់ខ្លួនក៏បានផ្ដិតមេដៃទៅលើលិខិតបញ្ជាក់ព្រំទៅឲ្យឈ្មោ[redacted] **សុផាត** ប៉ុន្តែពេលនោះ ដែលឈ្មោះ [redacted] **សុផាត** យកឯកសារទៅឲ្យប្ដីខ្លួនផ្ដិតមេដៃនោះគឺនៅអំឡុងឆ្នាំ២០០៤។ បានជារូបខ្លួនអះអាងថា ដីចំការដែលមានទីតាំងស្ថិតនៅភូមិពូលូង សង្កាត់រមនា ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី ជាដីចំការរបស់ ឪពុកម្ដាយរបស់ខ្លួនបាន ព្រោះឪពុកម្ដាយរបស់ខ្លួនអាស្រ័យផលតាំងពីឆ្នាំ១៩៩៤ មកម្លេះ និងបានដាំ ដំណាំកាហ្វេ ធូរេន និងដំណាំផ្សេងៗទៀត និងបានធ្វើផ្ទះ និងរស់នៅទីនោះផងដែរ ព្រមទាំងបានចិញ្ចឹមគោ ,មាន់ នៅទីនោះ ថែមទៀតផង។ ខ្លួនមានសាក្សីដឹងឮដែលពួកគាត់អះអាងថា ដីចំការដែលមានទីតាំងខាងលើនោះ ជាដីចំការ ឪពុកម្ដាយរបស់ខ្លួន គឺមានឈ្មោះ [redacted] **សុខា** ,ឈ្មោះ [redacted] **សាផាន** , ឈ្មោះ [redacted]កាំពី និងឈ្មោះ [redacted] **ញ៉ក** ។ ខ្លួនពុំបានបញ្ជាឲ្យអ្នកណាទៅប្រើអំពើហិង្សាលើជនរងគ្រោះណាឡើយ។

៦.តាមអំណានចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សារ៉ាន់** បានឆ្លើយបំភ្លឺថាៈ កាលពីឆ្នាំ២០០៧ ខ្លួនទិញដីពីឈ្មោះ [redacted] **សុផាត** ស្ថិតនៅភូមិពូលូង ឃុំរមនា ស្រុកសែនមនោរម្យ ខេត្តមណ្ឌលគិរី ទំហំ ៦៧៥៥០ ម៉ែត្រការ៉េ ព្រមទាំងបានធ្វើលិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លីលេខ **១៩៨/០៧** ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០៧ ដោយមានសាក្សី និងអាជ្ញាធរ ភូមិឃុំ ដឹងឮ ព្រមទាំងមានការឯកភាពផ្ដិតមេដៃទទួលស្គាល់ព្រំដីពីអ្នកដែលមានព្រំដីជាប់គ្នាផងដែរ។ ក្រោយមកនៅឆ្នាំ២០០៧ ហ្នឹងដដែល ខ្លួនបានធ្វើការឈូសឆាយលើដីនេះទាំងស្រុងព្រមទាំងបានដាក់បង្គោល(ឈើ) របងព្រំថែមទៀតផង។ លុះដល់ឆ្នាំ២០១៤ ខ្លួនក៏បានធ្វើការឈូសឆាយម្ដងទៀត។ រហូតដល់ឆ្នាំ២០១៧ ខ្លួនបានចាប់ផ្ដើមធ្វើការឈូសឆាយសារជាថ្មី និងបានដាក់បង្គោលជើងតាំងបន្ថែមត្រង់ចំណុចជ្រុងដីខាងលើ។ នៅថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២០ ខ្លួនបានដាក់បង្គោលរបងម្ដងទៀតនៅលើដីរបស់ខ្លួន។ ក្រោយមកនៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០ ឈ្មោះ [redacted] **សាវ៉ន** ,ឈ្មោះ [redacted] **សុផល** ,ឈ្មោះ [redacted] **សាឡួន** ,ឈ្មោះ [redacted] **រតនា** និងបក្ខពួកបានយកគ្រឿងចក្រមកឈូសឆាយនៅលើដី ខ្លួនឃើញសកម្មភាពឈូសឆាយនេះដោយផ្ទាល់ ខ្លួនក៏បានប្ដឹងទៅអាជ្ញាធរសង្កាត់រមនា និងអាជ្ញាធរក្រុងសែនមនោរម្យ ដើម្បីឲ្យធ្វើការហាមឃាត់ និងដោះស្រាយជូនខ្លួន។ ហើយអាជ្ញាធរក៏បានចុះទៅធ្វើការហាមឃាត់ដោយផ្ទាល់ពួកគេក៏បានផ្អាកសកម្មភាពទាំងនេះ។ ក្រោយមកខ្លួនក៏រង់ចាំការដោះស្រាយពីអាជ្ញាធរ។ មានឈ្មោះ [redacted] **សាវ៉ន** ,ឈ្មោះ [redacted] **សុផល** ,ឈ្មោះ [redacted] **សាឡួន** ,ឈ្មោះ [redacted] **តនា** និងបក្សពួក (មិនស្គាល់ ឈ្មោះ) បានស្រែកជេរខ្លួនទូវពាក្យអសុរសជាច្រើន ប៉ុន្តែធ្វើសកម្មភាពស្រែកជេរខ្លាំងជាងគេឈ្មោះ [redacted] **សាវ៉ន** និងឈ្មោះ [redacted] **សាឡួន**។ ចំពោះការខូចខាតរួមមានបង្គោលរបងថ្មអស់រាប់រយដើម ព្រមទាំងបង្កការរាំងស្ទះដល់ការងាររបស់ខ្លួនព្រមទាំងពេលវេលាផងដែរ។ ហើយក៏មានអាជ្ញាធរលោក [redacted] **អ៊ូន** អភិបាលរងក្រុងសែនមនោរម្យ បានចូលរួមចុះហាមឃាត់ដោយផ្ទាល់ និងសំណូមពរមកតុលាការឲ្យជួយរកយុត្តិធម៌ដល់រូបខ្លួនផង ហើយខ្លួនទាមទារ សំណងជម្ងឺចិត្ត ចំនួន **១០០.០០០** (ដប់ម៉ឺន) ដុល្លារអាមេរិក។

៧.តាមអំណានចម្លើយសាក្សីឈ្មោះ [redacted] **អ៊ូន** បានឆ្លើយបំភ្លឺថាៈ ខ្លួនបានពិនិត្យ និងដោះស្រាយលើពាក្យបណ្ដឹងរបស់ឈ្មោះ [redacted] **ហាវ៉ន** ,ឈ្មោះ [redacted] **ផល** ,ឈ្មោះ [redacted] **រតនា** និងឈ្មោះ [redacted] **សាឡួន** ប្ដឹងឈ្មោះ [redacted] **សារ៉ាន់** ប៉ុន្តែឈ្មោះ [redacted] **សូរិយា** ធ្វើជាអ្នកតំណាងឲ្យឈ្មោះ [redacted] **សារ៉ាន់**។ នៅពេលដែលបានទទួលពាក្យបណ្ដឹងរួចមក ក៏បានធ្វើការកោះហៅភាគីទាំងសងខាងធ្វើការដោះស្រាយវិវាទ។ ក្រោយមកភាគីតំណាង



Scanned with CamScanner

ឈ្មោះ [redacted] សុរិយា ក៏បានចូលរួមព្រមទាំងមានឯកសារលិខិតកាន់កាប់ដីធ្លីលេខ ១៩៨ ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០០៧ ដោយឡែកភាគីឈ្មោះ [redacted] សុផល ពុំមានឯកសារពាក់ព័ន្ធការកាន់កាប់ដីទំនាស់ខាងលើនេះទេ និងពុំបានឆ្លើយបំភ្លឺអ្វីទេ ព្រមទាំងមានកាយវិការមិនសមរម្យនៅចំពោះមុខអាជ្ញាធរថែមទៀតផង។ នៅថ្ងៃកើតហេតុអំឡុងខែមិថុនា ឆ្នាំ២០២០ វេលាម៉ោងប្រហែលជាពេលរសៀល ខ្លួនជាអាជ្ញាធរបានដឹកនាំក្រុមការងារចុះទៅធ្វើការហាមឃាត់ សកម្មភាពឈូសឆាយរបស់ឈ្មោះ [redacted] សាវ៉ន។ បន្ទាប់មកភាគី ឈ្មោ[redacted] សាវ៉ន ,ឈ្មោះ [redacted] សុផល ,ឈ្មោះ [redacted] រតនា និងឈ្មោះ [redacted] សាឡុន បានជេរប្រមាថនូវពាក្យអសុរសជាច្រើនមកលើឈ្មោះ [redacted] សាវ៉ាន់ ពិតប្រាកដមែន។ ក្រោយមកភាគីខាងឈ្មោះ [redacted] សាវ៉ន ក៏បានផ្អាកសកម្មភាពរហូតមកដល់បច្ចុប្បន្នតែម្តង។

៨.តាមចម្លើយសាក្សីឈ្មោះ [redacted] ខុច បានឆ្លើយបំភ្លឺថា: ខ្លួនបានស្គាល់ឈ្មោះ [redacted] សាវ៉ាន់ នៅអំឡុងឆ្នាំ២០០០ មកម្ល៉េះ ដោយសារពេលនោះខ្លួនធ្វើជាប៉ូលីសនៅខេត្តមណ្ឌលគិរី ហើយឈ្មោះ [redacted] សាវ៉ាន់ ជាទាហ៊ានកងវិស្វកម្ម។ ខ្លួនបានដឹងថាឈ្មោះ [redacted] សាវ៉ាន់ ទិញដីដែលកំពុងមានទំនាស់ខាងលើ ស្ថិតនៅភូមិពូលូង សង្កាត់រមនា ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី ពីឈ្មោះ [redacted] សុជាត កាលពីអំឡុងឆ្នាំ២០០៧ មកម្ល៉េះ។ ចំណែកឈ្មោ[redacted] សុជាត ត្រូវជាបងប្អូនរាប់អានគ្នាជាមួយខ្លួន ហើយខ្លួនក៏បានឃើញពិតប្រាកដថា ឈ្មោះ [redacted] សាវ៉ាន់ បានដាក់បង្គោលរបងឈើ និងបង្គោលរបងថ្មជាបន្តបន្ទាប់ ព្រមទាំងមានការឈូសឆាយជារៀងរាល់ឆ្នាំ បន្ទាប់ពីទិញដីខាងលើពីឈ្មោះ [redacted]ជាត។ លុះក្រោយមកនៅថ្ងៃមិនចាំអំឡុងខែមិថុនា ឆ្នាំ២០២០ វេលាម៉ោងប្រហែលជា៩ ជាងព្រឹក ខ្លួនបានឃើញមានអាជ្ញាធរក្រុង ចុះទៅធ្វើការផ្អាកសកម្មភាពគ្រឿងចក្រដែលកំពុងធ្វើការឈូសឆាយរបស់ឈ្មោះ [redacted] សាវ៉ន ព្រមទាំងមានការជជែកគ្នា។ បន្ទាប់មក ឈ្មោះ [redacted] រតនា ហៅ ជី ជាប្អូនបង្កើតរបស់ឈ្មោះ [redacted] សាវ៉ន បានជេរនៅពាក្យអសុរសមកលើឈ្មោះ [redacted] សាវ៉ាន់ ប្រាកដមែន។

៩.តាមអំណានចម្លើយសាក្សីឈ្មោះ [redacted]សូរិយា បានឆ្លើយបំភ្លឺថា: ខ្លួនដឹងថាឈ្មោះ [redacted] សាវ៉ាន់ បានទិញដីដែលកំពុងមានទំនាស់ខាងលើពីឈ្មោះ [redacted] សុជាត កាលពីឆ្នាំ២០០៧ មកម្ល៉េះ។ ខ្លួនដឹងដោយសារតែមុនមកខ្លួនក៏ធ្លាប់លក់ដីឱ្យគាត់ដែរ ហើយខ្លួនក៏ធ្លាប់ទៅឈូសឆាយទីតាំងខាងលើកាលពីឆ្នាំ២០០៧ ឈូសឆាយបានចំនួន០១ លើក និងឆ្នាំ២០១២ ឈូសឆាយដីព្រមទាំងធ្វើផ្លូវ និងដាក់បង្គោលរបង ព្រំបន្ថែម និងនៅឆ្នាំ២០១៧ ខ្លួនក៏បានឈូសឆាយដីខាងលើព្រមទាំងដាក់បង្គោលថ្មម្តងទៀត ហើយការឈូសឆាយ ចំនួន០២ដងមកនេះ គឺពុំមាននរណាមកហាមឃាត់ និងរករឿងនោះទេ លុះដល់ឆ្នាំ២០២០ ឈ្មោះ [redacted] សាវ៉ាន់ ឱ្យឈូសឆាយដីនេះម្តងទៀត។ លុះនៅថ្ងៃកើតហេតុប្រហែលជាថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០ វេលាម៉ោងប្រហែល៩ ព្រឹក ខ្លួនទៅឈូសឆាយដីខាងលើ និងដាក់បង្គោលព្រំថ្មថែម ជាមួយឈ្មោះ [redacted] សាវ៉ាន់ ព្រមទាំងកម្មករ ស្រាប់តែមានមនុស្សមួយក្រុមជិះឡាន ម៉ាកពីរបាំង និងមានគ្នាប្រហែលជា១០ នាក់ ប៉ុន្តែខ្លួនស្គាល់តែឈ្មោះ [redacted] សាវ៉ន ,ឈ្មោ[redacted] រតនា ,ឈ្មោះ [redacted] សុផល និងឈ្មោះ [redacted] ឡុន ចំណែកអ្នកផ្សេងទៀតខ្លួនមិនស្គាល់ឈ្មោះទេ ដោយពួកគេបានធ្វើការហាមឃាត់មិនឱ្យធ្វើការឈូសឆាយលើដីខាងលើ។ ហើយឈ្មោះ [redacted] សាវ៉ន បានបញ្ជាឱ្យកូនចៅរបស់ពួកគេកាច់បង្គោលថ្មរស់ជាច្រើនដើម និងបានជេរប្រមាថនូវពាក្យអសុរសជាច្រើនមកកាន់ខ្លួន និងឈ្មោះ [redacted]ាវ៉ាន់ ហើយខ្លួន និងឈ្មោះ [redacted] សាវ៉ាន់ ពុំបានធ្វើការតបតអ្វីនោះទេ។ ក្រោយមកនៅម៉ោងប្រហែលជា១១ ព្រឹក ឈ្មោះ [redacted] សាវ៉ាន់ ក៏បានខល



Scanned with CamScanner

ប្ដឹងទៅអាជ្ញាធរក្រុងសែនមនោរម្យ ដើម្បីចុះមកពិនិត្យទីតាំងកំពុងមានទំនាស់ខាងលើ ហើយអាជ្ញាធរក្រុងសែន-មនោរម្យ ក៏បានឱ្យឈ្មោះ [redacted]សាវ៉ាន់ ផ្អាកសកម្មភាពឈូសឆាយដី និងដាក់បង្គោល ភ្លាមៗតែម្ដង ដោយរង់ចាំការដោះស្រាយសិន។ ក្រោយមកប្រហែលជា ២ ទៅ ៣ ថ្ងៃបន្ទាប់ឈ្មោះ [redacted] សាវ៉ន ក៏បានយកគ្រឿងចក្រទៅធ្វើការឈូសឆាយលើដីខាងលើ បន្ទាប់មកឈ្មោះ [redacted]សាវ៉ាន់ បានប្ដឹងទៅអាជ្ញាធរ ម្ដងទៀត ហើយអាជ្ញាធរក្រុងសែនមនោរម្យ បានចុះទៅធ្វើការហាមឃាត់សកម្មភាពកំពុងឈូសឆាយ។ នៅពេលនោះ ឈ្មោះ [redacted] សាវ៉ន ក៏បានជេរប្រមាថមកពួកខ្លួន និងអាជ្ញាធរនូវពាក្យអសុរសជាច្រើនព្រមទាំងធ្វើការនិយាយបំភ្លៃថា ឈ្មោះ **កែវ សាវ៉ាន់** បានយកកាំភ្លើងគំរាមប្អូនរបស់គាត់ឈ្មោះ [redacted]**រតនា**។

១០.តាមចម្លើយសាក្សីឈ្មោះ [redacted] **ប៊ុក** បានឆ្លើយបំភ្លឺថា: នៅឆ្នាំ១៩៨៩ ខ្លួនជាសមាជិក លុះឆ្នាំ១៩៩៣ ខ្លួនបានធ្វើជាមេភូមិពូលួង ហើយនៅឆ្នាំ២០០៦ មានការបោះឆ្នោតជ្រើសរើសមេភូមិ ពេលនោះឈ្មោះ [redacted]**ស្រើន** ជាប់ជាមេភូមិ ហើយខ្លួនជាអនុភូមិ រហូតមកដល់ឆ្នាំ២០១៧ ខ្លួនក៏បានឡើងធ្វើជាមេភូមិម្ដងទៀត។ ចំពោះឈ្មោះ [redacted]**រតនា** ,ឈ្មោះ [redacted] **សាវ៉ន** ,ឈ្មោះ [redacted]**សុផល** និងឈ្មោះ [redacted] **ឡូន** ព្រមទាំងឈ្មោះ [redacted] **សាវ៉ាន់** ខ្លួនស្គាល់ច្បាស់គឺឈ្មោះ [redacted] **ឡូន** ក្រៅពីនោះធ្លាប់តែឮឈ្មោះ ប៉ុន្តែមិនស្គាល់មុខ។ ហើយខ្លួនក៏មិនដឹងច្បាស់ទេថា ពួកគេមានទំនាស់ដីធ្លី គ្រាន់តែដឹងថាឈ្មោះ [redacted] **សាវ៉ាន់** ធ្លាប់ប្រមូលទិញដីពីប្រជាពលរដ្ឋនៅម្ដុំខាងក្រោយផ្សារថ្មី ផ្លូវក្រវ៉ាត់ក្រុង ដែលស្ថិតនៅភូមិពូលួង សង្កាត់រមនា ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី។ កន្លងមកខ្លួនពុំធ្លាប់ឃើញឈ្មោះ [redacted]**រតនា** ,ឈ្មោះ[redacted] **សាវ៉ន** ,ឈ្មោះ [redacted] **សុផល** និងឈ្មោះ [redacted] **ឡូន** ចូលកាន់កាប់ និងធ្វើស្រែចំការលើដីនោះទេ ប៉ុន្តែពួកគេមានដីក្បែរនោះដែរ មានចំងាយពីគ្នាប្រហែលជា ៥០០ ម៉ែត្រ ប៉ុន្តែខ្លួនមិនដឹងថាដីចំការរបស់ពួកគេមានទំហំប៉ុន្មានឡើយ។ ហើយកន្លងមកខ្លួន ក៏មិនដឹងថា ឈ្មោះ [redacted] **យឿន** ធ្លាប់បានកាន់កាប់ដីនៅទីនោះទេ។

១១.តាមចម្លើយសាក្សីឈ្មោះ [redacted] **សុផាត** បានឆ្លើយបំភ្លឺថា: ក្នុងឆ្នាំ២០០៧ ខ្លួនបានលក់ដីដែលមានទំហំប្រហែល ប្រាំមួយហិកតាជាង ស្ថិតនៅភូមិពូលួង ឃុំរមនា ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី ឱ្យទៅឈ្មោះ [redacted]**សាវ៉ាន់**។ ដីដែលខ្លួនលក់ទៅឱ្យឈ្មោះ [redacted]**សាវ៉ាន់** គឺមានព្រំដីជាប់ព្រំដីរបស់ឈ្មោះ [redacted] **យឿន** ពិតមែន មិនមែនជាដីជាន់គ្នានោះទេ។ ចំពោះសេចក្ដីបញ្ជាក់របស់អ្នកមានព្រំប្រទល់ដីជាប់គ្នា គឺខ្លួនជាអ្នកយកឯកសារផ្ដិតព្រំដីទៅឱ្យឈ្មោះ [redacted] **យឿន** ផ្ដិតមេដៃ ប៉ុន្តែឈ្មោះ [redacted] **យឿន** បានឆ្លើយ គាត់មិនមានសិទ្ធិទៀតទេ ពីព្រោះគាត់បានប្រគល់ដីឱ្យទៅកូនអស់ហើយ។ ពេលនោះឈ្មោះ [redacted] **យឿន** បានប្រាប់ខ្លួនឱ្យទៅជួបកូនគាត់ឈ្មោះ [redacted] **សាវ៉ន** និងឈ្មោះ [redacted]**សុផល**។ នៅពេលខ្លួនទៅជួបឈ្មោះ [redacted]**សាវ៉ន** និងឈ្មោះ [redacted]**សុផល** ហើយប្រគល់សេចក្ដីបញ្ជាក់របស់អ្នកមានព្រំប្រទល់ដីជាប់គ្នា ភ្លាមនោះឈ្មោះ **ចាន់ សាវ៉ន** និងឈ្មោះ [redacted] **សុផល** ក៏ព្រមផ្ដិតមេដៃតែម្ដង រួចខ្លួនក៏ត្រឡប់មកវិញ ហើយយកសេចក្ដីបញ្ជាក់របស់អ្នកមានព្រំប្រទល់ដីជាប់គ្នាឱ្យឈ្មោះ [redacted]**សុធី**។

១២.តាមចម្លើយសាក្សីឈ្មោះ [redacted] **សុខា**, ឈ្មោះ [redacted]**សុណារ** ,ឈ្មោះ [redacted]**ញ៉ឹត** ,ឈ្មោ[redacted] **បូរ៉េត** , ឈ្មោះ [redacted]**កំពី** ,ឈ្មោះ [redacted] **ទន់** ,និងឈ្មោ[redacted] **តិច** បានឆ្លើយបំភ្លឺប្រហាក់ប្រហែលគ្នាថា: ឈ្មោះ [redacted]**យឿន** ធ្លាប់ឱ្យពួកខ្លួនទៅជួយកាប់ឆ្ការដីរបស់គាត់ ពេលនោះឃើញនៅលើដីចំការនោះ មានចិញ្ចឹមគោ មានដំណាំផ្សេងៗ



Scanned with CamScanner

ដែលដំណាំខ្លះមានផ្លែ ហើយនៅជាប់ដីនោះ គ្មានចំការរបស់អ្នកផ្សេងទៀតទេ។ ចំពោះរឿងហេតុទាក់ទងនឹង ហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត និងបណ្ណកម្មសិទ្ធរបស់ឈ្មោះ[redacted] **ឃឿន** នោះ គឺខ្លួនមិនបានដឹងទេ។ ចំណុចខាងលើនេះ តុលាការយល់ឃើញថា គឺជាការអះអាងអំពីសិទ្ធិ ទាក់ទងនឹងរឿងរដ្ឋប្បវេណី គប្បីតុលាការមិនលើកយកមកពិចារណាទេ។

១៣.តាមលិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លីលេខ **១៩៨/០៧** ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០៧ ចុះហត្ថលេខាទទួលស្គាល់ដោយលោក [redacted] **ស្រ៊ើន** មេភូមិពូលូង និងឈ្មោះ [redacted] **សាវៀត** មេឃុំរមនា មានព្រំប្រទល់ខាងជើងទល់ [redacted] **សារ៉ាន់** ខាងត្បូងទល់ អូរ ខាងកើតទល់ [redacted] **សាវ៉ន** ខាងលិចទល់នឹង [redacted] **សារ៉ាន់** អាចបញ្ជាក់បានថា ឈ្មោះ [redacted] **សារ៉ាន់** ជាម្ចាស់កម្មសិទ្ធិដីទំនាស់នេះពិតប្រាកដមែន។

១៤.តាមសេចក្តីបញ្ជាក់របស់អ្នកមានព្រំប្រទល់ដីជាប់គ្នា លេខ **១២៣/០៧** ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០៧ មានផ្តិតស្នាមមេដៃអ្នកជាប់ព្រំ ឈ្មោះ [redacted] **សារ៉ាន់** ,ឈ្មោះ [redacted] **សុផល** និងឈ្មោះ [redacted]**សាវ៉ន** ហើយនៅពេលសវនាការឈ្មោះ [redacted] **សុផាត** បានអះអាងថា ខ្លួនពិតជាបានយកសេចក្តីបញ្ជាក់របស់អ្នកមានព្រំប្រទល់ដីជាប់គ្នា ឱ្យឈ្មោះ [redacted]**សុផល** និងឈ្មោះ [redacted]**សាវ៉ន** ផ្តិតមេដៃពិតប្រាកដមែន។

១៥.ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទឈ្មោះ [redacted]**ផល** ចម្លើយដើមបណ្តឹង សាក្សី និងក្រោយពីបានពិនិត្យភស្តុតាងនានានៅក្នុងសំណុំរឿង ក៏ដូចជា បញ្ជីសម្រង់វត្តមានប្រចាំថ្ងៃរបស់មន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យា ជាដើម អាចបញ្ជាក់បានថា: ជនជាប់ចោទឈ្មោះ[redacted]**សុផល** នៅថ្ងៃកើតហេតុពុំមានវត្តមាននៅកន្លែងកើតហេតុនោះទេ ហេតុនេះ គប្បីតុលាការពិចារណាឱ្យជនជាប់ចោទឈ្មោះ [redacted]**សុផល** រួចផុតពីបទចោទប្រកាន់ **ហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត** ប្រព្រឹត្តនៅចំណុចភូមិពូលូង សង្កាត់រមនា ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី កាលពីអំឡុងខែមិថុនា ឆ្នាំ២០២០។

១៦.ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ចម្លើយសាក្សី និងក្រោយពីបានពិនិត្យភស្តុតាង នានានៅក្នុងសំណុំរឿង អាចបញ្ជាក់បានថា: សកម្មភាពរបស់ជនជាប់ចោទឈ្មោះ [redacted] **រតនា** , ឈ្មោះ [redacted] **សាវ៉ន** ,និងឈ្មោះ[redacted] **ឡុន** ដែលបានដកបំផ្លាញបង្គោលរបងថ្មព្រំដី និងយកគ្រឿងចក្រមកឈូសឆាយដីរបស់ឈ្មោះ [redacted]**សារ៉ាន់** ដែលមានលិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លីលេខ **១៩៨/០៧** ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០៧ ទទួលស្គាល់ដោយអាជ្ញាធរ ភូមិឃុំ ចំណែកឯជនជាប់ចោទទាំងបីនាក់ ពុំមានលិខិតបញ្ជាក់ពីកម្មសិទ្ធិនោះទេ រហូតដល់សវនាជនជាប់ចោទទាំងបីនាក់ខាងលើ នៅតែគ្មានឯកសារបញ្ជាក់ពីភស្តុតាងណាមួយមកតុលាការឡើយ។ អំពើបែបនេះ គឺជាបទល្មើស **ហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត** ដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **២៤៨** និងមាត្រា **២៥៣** នៃច្បាប់ភូមិបាល ពិតប្រាកដមែន ។

១៧.មានពិរុទ្ធភាពគ្រប់គ្រាន់ក្នុងការដាក់បន្ទុកលើជនជាប់ចោទឈ្មោះ [redacted]**រតនា** , ឈ្មោះ [redacted]**ាវ៉ន** ,និងឈ្មោះ [redacted]**ឡុន** និងពុំមានពិរុទ្ធភាពគ្រប់គ្រាន់ក្នុងការដាក់បន្ទុកលើជនជាប់ចោទឈ្មោះ [redacted] **សុផល** ពីបទ: **ហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត** ប្រព្រឹត្តនៅចំណុចភូមិពូលូង សង្កាត់រមនា ក្រុងសែនមនោរម្យ ខេត្ត



Scanned with CamScanner

មិត្តលើគេ កាលពីអំឡុងខែមិថុនា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌទោសតាមមាត្រា ២៤៨ និងមាត្រា ២៥៣ ច្បាប់-ភូមិបាល។

១៨.ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សាវ៉ាន់ បានទាមទារសំណងជំងឺចិត្តចំនួន ៤០០,០០០,០០០ (បួនរយលាន) រៀល ពីឈ្មោះ [redacted] រតនា ,ឈ្មោះ [redacted] សុផល ,ឈ្មោះ [redacted] សាវ៉ន ,និងឈ្មោះ [redacted] ឡុន ប៉ុន្តែនៅក្នុងរឿងនេះ ពុំមានពិរុទ្ធភាពគ្រប់គ្រាន់ក្នុងការដាក់បន្ទុកទៅលើជនជាប់ចោទឈ្មោះ [redacted] សុផល ទេ គប្បីតុលាការមិនលើកយកឈ្មោះនេះមកពិចារណា។

## ហេតុដូច្នេះ វិនិច្ឆ័យសេចក្តី

១.ផ្តន្ទាទោសលើជនជាប់ចោទ

ក.ឈ្មោះ [redacted] **រតនា** ភេទប្រុស អាយុ៣៤ឆ្នាំ ជនជាតិខ្មែរ

ខ.ឈ្មោះ [redacted] **សាវ៉ន** ភេទស្រី អាយុ៤១ឆ្នាំ ជនជាតិខ្មែរ

គ.ឈ្មោះ [redacted] **ឡុន** ភេទប្រុស អាយុ៤៥ឆ្នាំ ជនជាតិព្នង

ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់រយៈពេល ០១ (មួយ) ឆ្នាំ ប៉ុន្តែទោសនេះត្រូវព្យួរទាំងស្រុង ពីបទ: **ហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត** ប្រព្រឹត្តនៅចំណុចភូមិពូលូង សង្កាត់រមនា ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី កាលពីអំឡុងខែមិថុនា ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា **២៤៨** និងមាត្រា **២៥៣** នៃច្បាប់ភូមិបាល និងមាត្រា **១០៧** ,មាត្រា **១០៨** នៃក្រមព្រហ្មទណ្ឌ។

២.ឱ្យជនជាប់ចោទឈ្មោះ [redacted] សុផល ភេទស្រី អាយុ៤០ឆ្នាំ ជនជាតិព្នង រួចផុតពីបទចោទ: **ហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត** ប្រព្រឹត្តនៅចំណុចភូមិពូលូង សង្កាត់រមនា ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី កាលពីអំឡុងខែមិថុនា ឆ្នាំ២០២០។

៣.បង្គាប់ឱ្យជនជាប់ចោទឈ្មោះ [redacted] **រតនា** ,ឈ្មោះ [redacted] **សាវ៉ន** និងឈ្មោះ [redacted] **ឡុន** រួមគ្នាសងសំណងរដ្ឋប្បវេណីទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សាវ៉ាន់** ចំនួន ១២,០០០,០០០ (ដប់ពីរលាន) រៀល។

៤.សាលក្រមនេះជំនុំជម្រះជាសាធារណៈ និងប្រកាសជាសាធារណៈ នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] **សុផល** កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] **រតនា** ,ឈ្មោះ [redacted] **សាវ៉ន** ,ឈ្មោះ [redacted] **ឡុន** និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សាវ៉ាន់**។

-ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ជាធរមាន។

**ក្រឡាបញ្ជីសវនាការ** — ហត្ថលេខា និងត្រា [redacted]

**ចៅក្រមជំនុំជម្រះ** — ហត្ថលេខា និងត្រា [redacted]

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម**

ថ្ងៃពុធ ៤កើត ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

មណ្ឌលគិរី,ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២១

**ក្រឡាបញ្ជី**

**បានឃើញ**

**ចៅក្រមជំនុំជម្រះ**

[redacted]

[redacted]



Scanned with CamScanner